សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


**កិច្ចការស្រាវជ្រាវ**

# សិទ្ធិរបស់នីតិបុគ្គល

កិច្ចការស្រាវជ្រាវពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤

សាស្ត្រាចារ្យបង្រៀន

អ្នកគ្រូ **ស្រី វណ្ណធី**

មុខវិជ្ជា **នីតិរដ្ឋប្បវេណី**


រៀបរៀងដោយ

និស្សិតឈ្មោះ លោក **ថាត ចាន់ថា** លោក **ដួង ខេមរា**

លោក **យៀន ប៊ុនហាវ** លោក **អ៊ុន ដាវីឌ**

កញ្ញា **គន្ធ គីមហេង**


បរិញ្ញាបត្រ **នីតិសាស្ត្រ**

ថ្នាក់ *L2B5*

ក្រុមទី **៤**

ប្រធានបទទី **៤**

ឆ្នាំចូលសិក្សា **២០១២**

និស្សិតឆ្នាំទី **II**

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## កិច្ចការស្រាវជ្រាវ

# សិទ្ធិរបស់នីតិបុគ្គល

**សាស្ត្រាចារ្យបង្រៀន**

អ្នកគ្រូ **ស្រី វណ្ណធី**

មុខវិជ្ជា **នីតិរដ្ឋប្បវេណី**

**គាក់តែងឡើងដោយ**

| | | | |
|---|---|---|---|
| និស្សិតឈ្មោះ | លោក | **ថាត** | **ចាន់ថា** |
| | លោក | **ដួង** | **ខេមរា** |
| | លោក | **អ៊ុន** | **ដាវីឌ** |
| | លោក | **យៀន** | **ប៊ុនហាច** |
| | កញ្ញា | **គន្ធ** | **គីមហេង** |

| | | | |
|---|---|---|---|
| ថ្នាក់ | **បរិញ្ញាបត្រ** | ឆ្នាំចូលរៀន | ២០១២ |
| ជំនាញ | **នីតិសាស្ត្រ** | ការពារកិច្ចការស្រាវជ្រាវ | ១៣/ ០១/ ២០១៤ |
| ថ្នាក់ | **L2B5** | | |
| ក្រុមទី៤ | | | |

# អារម្ភកថា

សៀវភៅដែលលោកអ្នកកំពុងតែកាន់អាននេះ គឺជាវណ្ណកម្មរបស់ក្រុមយើងខ្ញុំនៃថ្នាក់$L_2B_5$ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលក្រុមរបស់យើងខ្ញុំបានខិតខំព្យាយាមស្រាវជ្រាវសរសេរឡើង ដើម្បីទុកជាចំណងដៃសម្រាប់អស់លោកអ្នកដែលស្នេហានិស្ស័យវិស័យចំណេះដឹងនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ហេតុដែលក្រុម របស់យើងខ្ញុំព្យាយាម សរសេរនេះ គឺក្រុមយើងខ្ញុំយល់ឃើញថាសៀវភៅ ក្បួនច្បាប់ផ្សេងៗ ផ្នែកសីលធម៌នៅក្នុងសង្គម របស់ប្រទេសកម្ពុជាយើងដែលបានបាត់បង់ជាច្រើន នៅពេលប្រទេសយើងជួបវិបត្តិ។ ពេលនោះគឺជា កំឡុងពេល ដ៏អាក្រក់ដែលសៀវភៅ ក្បួនច្បាប់ផ្សេងៗដែលជាស្នាដៃរបស់អ្នកនិពន្ធ រៀមច្បងយើងខំបង្កើតឡើង ទុកឲ្យយើងជាជាតិខ្មែរ ជំនាន់ក្រោយសម្រាប់រៀនសូត្រត្រូវបានបំផ្លាញ។ ឥឡូវនេះក្រុមយើងខ្ញុំមានកាលានុវត្តភាព ជួបជាមួយអស់លោកអ្នក តាមរយៈសំនេររបស់ក្រុមយើងខ្ញុំ ទុកជាចំណងដៃ សម្រាប់លោកអ្នកអានក្នុងសហស្សវត្សន៍ថ្មីនេះ។ ហើយម្យ៉ាងទៀតកម្រងឯកសារដែលបានលើកឡើងក្នុងអត្ថបទដែលមិត្តអ្នកអាន និស្សិត លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ កំពុងតែអាននេះ មានចំណងជើង ជាខេមរភាសាថា "**សិទ្ធិរបស់នីតិបុគ្គល**" ។

ខ្ញុំសង្ឃឹម និង ជឿជាក់ថានៅក្នុងការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំនេះទោះបីជាមានការខិតខំព្យាយាមពិនិត្យផ្ទៀងផ្ទាត់យ៉ាងណាក៏ដោយក៏នៅតែមានភ្លាំងភ្លាត់ខុសឆ្គងខ្លះៗ ដោយអចេតនាពុំខាន។បើដូច្នេះខ្ញុំសូមអរភ័យទោស អំពីសំណាក់ អស់លោក មិត្តអ្នកអានទុកជាមុននូវរាលកំហុសឆ្គងទាំងឡាយដែលអាចកើតមានដោយចេតនាក្តី អចេតនាក្តី សូមខន្តីអរភ័យទោសដោយការគោរពយ៉ាងស្មោះស្មគ្រ័ពីសំណាក់ក្រុមរបស់យើងខ្ញុំ ហើយក៏ទទួលស្វាគមន៍នូវរាល់ការរិះគន់បែបស្ថាបនាដើម្បីកែលំអព្រមទាំងបន្ថែមនូវគំនិតល្អៗដើម្បីបន្សល់ទុកឲ្យកូនខ្មែរជំនាន់ក្រោយក្នុងការសិក្សា។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធពរដល់មិត្តអ្នកអានទាំងអស់ ដែលជាក្រុមនិស្សិត លោកគ្រូ អ្នកគ្រូ ក៏ដូចជាប្រជាពលរដ្ឋខ្មែរគ្រប់រូបឲ្យជួបប្រទះតែសំណាង សុខភាពល្អ និងទទួលបាននូវជោគជ័យនៅក្នុងជីវិតគ្រប់ភារកិច្ច។

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០១៣

និស្សិតជំនាញនីតិសាស្ត្រថ្នាក់ $L_2B_5$

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមក្រុមរបស់យើងខ្ញុំជាសិស្សនិស្សិតឆ្នាំសិក្សា២០១៣-២០១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ជាការសិក្សាស្រាវជ្រាវទៅលើ **សិទ្ធរបស់នីតិបុគ្គល** បានបញ្ចប់នូវដំណើរការនៃការស្រាវជ្រាវ និង ចេញរបាយការណ៍របស់ខ្លួនដោយជោគជ័យជាស្ថាពរពេលនេះ។ ក្នុងន័យនេះ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ :

- មាតាបិតាយើងខ្ញុំ ដែលបានផ្តល់កំណើត ជួយផ្គត់ផ្គង់ ជ្រោមជ្រែង ឧបត្ថម្ភទាំងសម្ភារៈ និង ថវិកា គ្រប់បែបយ៉ាង ព្រមទាំងជំរុញលើកទឹកចិត្ត ឲ្យយើងខ្ញុំបានសិក្សាក្រេបយកចំនេះដឹង និង ក្លាយជាពលរដ្ឋល្អក្នុងសង្គមថ្ងៃនេះ។
- មិត្តរួមក្រុមរបស់យើងខ្ញុំដែលបានចំណាយពេលវេលាដ៏មានតម្លៃធ្វើការស្រាវជ្រាវយ៉ាងម៉ត់ចត់ទៅលើប្រធានបទនេះហើយចេះសហការគ្នាធ្វើការស្រាវជ្រាវយ៉ាងជិតស្និតដោយមិនគិតពីការនឿយហត់ដោយបញ្ចេញមតិយោបល់យ៉ាងច្រើនទើបសម្រេចបានជាកម្រងឯកសារមួយនេះ។
- ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈកម្មការ និង សាស្រ្តាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានខិតខំដឹកនាំ និង គ្រប់គ្រងក្នុងគោលបំណងបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីជាសសរទ្រូងប្រទេស។
- សាស្រ្តាចារ្យ **ស្រី វណ្ណធី** ដែលជាសាស្រ្តចារ្យបង្រៀនមុខវិជ្ជា **នីតិរដ្ឋប្បវេណី** ដែលបានយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀន ជួយលើកទឹកចិត្ត ត្រួសត្រាយផ្លូវ និង ផ្តល់នូវដំបូន្មានល្អៗ។
- លើសពីនេះ សូមអរគុណដោយស្មោះស្ម័គ្រ និង មោទនភាពជាតិបំផុតចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំ ដែលបាន នឹងកំពុងដឹកនាំនាវាកម្ពុជាលើផ្លូវនយោបាយដ៏ត្រឹមត្រូវមួយប្រកបដោយសុច្ចរិតភាព រក្សាបាននូវសុខសន្តិភាព ស្ថេរភាព និង ការអភិវឌ្ឍន៍ ហើយដែលជាការផ្តល់ឱកាសយ៉ាងប្រសើរ សំរាប់ការសិក្សា និង ការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំនាពេលនេះ។

ជាទីបញ្ចប់ សូមប្រសិទ្ធិពរជ័យ សិរីសួរស្តី វិបុលសុខ បវរមហាប្រសើរដល់លោកអ្នកមានគុណទាំងអស់ទទួលបានជោគជ័យគ្រប់ភារកិច្ច និង សុខភាពរឹងមាំទទួលទានគ្រប់ៗគ្នា ព្រមទាំងពុទ្ធពរទាំងប្រាំប្រការទៀតគឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**ទំព័រ**

**អារម្ភកថា**.......................................................................i
**សេចក្ដីថ្លែងអំណរគុណ**...........................................................ii
**មាតិកា**...........................................................................iii
**I- សេចក្ដីផ្ដើម**......................................................................១
១- លំនាំបញ្ហានៃការស្រាវជ្រាវ.........................................................១
២- ចំណោទបញ្ហានៃការស្រាវជ្រាវ......................................................២
៣- កម្មវត្ថុនៃការស្រាវជ្រាវ.............................................................២
៤- សារៈសំខាន់នៃការស្រាវជ្រាវ.......................................................២
**II- និយមន័យ**...........................................................................៣
**III- ប្រភេទនៃនីតិបុគ្គល**...............................................................៤
១- នីតិបុគ្គលសាធារណៈ..................................................................៤
២- នីតិបុគ្គលឯកជន......................................................................៥
២.១- នីតិបុគ្គលមូលនិធិ...................................................................៥
២.២- ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត......................................៦
២.៣- ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត.........................................៧
២.៤- នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត..................................៨
២.៥- នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត...................................៨
**IV- គោលការណ៍នៃការបង្កើតនីតិបុគ្គល**...........................................១០
១- ការចុះបញ្ជីនៃការបង្កើត..............................................................១០
២- លំនៅដ្ឋាននៃនីតិបុគ្គល..............................................................១១
២.១- ការចុះបញ្ជីអំពីការផ្លាស់ប្ដូរទីតាំងភ្នាក់ងារ.......................................១២
២.២- ការចុះបញ្ជីទីស្នាក់ការដែលបង្កើតថ្មី............................................១២
២.៣- ការគ្រប់គ្រង និង ការចាត់ចែងកិច្ចការនៃនីតិបុគ្គល...............................១២
២.៣.១- បញ្ជីទ្រព្យសម្បត្តិ និង បញ្ជីរាយនាមសមាជិក.................................១២
២.៣.២- ចំនួនការជ្រើសតាំង ការដកហូតតំណែង និង ភារកិច្ចនៃអភិបាល........១៣
**V- ការចុះបញ្ជីពាណិជ្ជកម្មរបស់ពាណិជ្ជករជានីតិបុគ្គល**..............................១៣
១- នីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្ម....................................................១៤
១.១- ប្រភេទក្រុមហ៊ុនដែលអនុញ្ញាតិដោយក្រសួងពាណិជ្ជកម្ម.........................១៤

១.២- ការចុះបញ្ជីប្រថាប់ត្រានូវសារលិខិតបង្កើតក្រុមហ៊ុន.......................................១៤
១.៣- ការចុះផ្សាយក្នុងសារព័ត៌មានស្របច្បាប់..........................................................១៤
១.៤- ការតំកល់នៅការិយាល័យក្រឡាបញ្ជី...............................................................១៥
១.៥- ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម.......................................................................១៦
ក- លក្ខខណ្ឌនានានៃការចុះបញ្ជី.........................................................................១៦
ខ- នីតិវិធីនៃការចុះបញ្ជី.........................................................................................១៧
ខ.១- សហគ្រាសឯកបុគ្គល..................................................................................១៧
ខ.២- ទម្រង់ការសំរាប់ចុះបញ្ជីសហគ្រាសសាធារណៈ............................................១៩
ខ.៣- ទម្រង់ការសំរាប់ចុះបញ្ជីតំណាង និងសាខាក្រុមហ៊ុនបរទេស.........២០
ខ.៤- ពាក្យសុំចុះបញ្ជីពាណិជ្ជកម្មត្រូវបង្កើតជា ៣ច្បាប់..........................២២
ខ.៥- ការផ្ញើរទុកពាក្យសុំ.......................................................................................២២
ខ.៦- ការបញ្ជូនពាក្យសុំ.........................................................................................២៣
១.៦- កម្រៃរដ្ឋបាលក្នុងការចុះឈ្មោះក្រុមហ៊ុន លុបឈ្មោះ និងចេញវិញ្ញាបនបត្រ......២៤
១.៧- បែបបទ និងនីតិវិធីកែប្រែលក្ខន្តិកៈ...................................................................២៥
២- ការចុះបញ្ជីអាជ្ញាបណ្ណនៅក្នុងក្រសួងស្ថាប័នពាក់ព័ន្ធ.................................................២៥
២.១- ពន្ធ និង ពន្ធប្រថាប់ត្រា....................................................................................២៥
២.២- ការបង់ពន្ធ.........................................................................................................២៦
២.៣- ពន្ធប៉ាតង់..........................................................................................................២៨
៣- ការរំលាយ និង ការជម្រះបញ្ជីក្រុមហ៊ុន.......................................................................២៨
៣.១- ការរំលាយក្រុមហ៊ុនយោងតាមឆន្ទះរបស់សមាជិកក្រុមហ៊ុន...........................២៩
៣.២- ការរំលាយក្រុមហ៊ុនទៅតាមកម្មវត្ថុរបស់ក្រុមហ៊ុន...........................................២៩
៣.៣- ក្រុមហ៊ុនក្ស័យធន............................................................................................៣០
៣.៤- ការជម្រះបញ្ជីក្រុមហ៊ុន.....................................................................................៣០
**VI- ការចុះបញ្ជីអង្គការសមាគមជានីតិបុគ្គល**.......................................................................៣១
១- លក្ខខណ្ឌនៃការបង្កើតអង្គការសមាគម.........................................................................២១
២- សំណុំលិខិតសុំចុះបញ្ជីសមាគម...................................................................................៣២
៣- សំណុំលិខិតសុំចុះបញ្ជីអង្គការក្រៅរដ្ឋាភិបាល...............................................................៣២
**VII- សេចក្តីសន្និដ្ឋាន និង អនុសាសន៍**.....................................................................................៣៣
១- សេចក្តីសន្និដ្ឋាន..........................................................................................................៣៣
២- អនុសាសន៍.................................................................................................................៣៣
**ឧបសម្ព័ន្ធ**
**ឯកសារយោង**

# សិទ្ធិរបស់នីតិបុគ្គល

**(Droits légaux)**

## I- សេចក្តីផ្តើម

### ១- លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា នៅតែទទួលរងនូវផលវិបាកពីកេរ្តិ៍តំណែលនៃសង្គ្រាមស៊ីវិលជាង ២០ ឆ្នាំ ចាប់តាំងពីឆ្នាំ ១៩៧០ ដល់ ឆ្នាំ ១៩៩០។ ក្នុងអំឡុងពេលនោះចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នៃ បញ្ញវន្ត ខ្មែរបានរត់ចេញពីប្រទេស និង មួយចំនួនទៀតត្រូវបានសម្លាប់ ចំណែកឯរចនាសម្ព័ន្ធរាជរដ្ឋាភិបាល មិនមានប្រតិបត្តិការពេញលេញឡើយ។ ហេដ្ឋារចនាសម្ពន្ធ័ ផ្នែកសង្គម និង សេដ្ឋកិច្ចត្រូវបាន បំផ្លាញទាំងស្រុងក្នុងរបបខ្មែរក្រហម។ សព្វថ្ងៃនេះប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំនោម ប្រទេសក្រីក្របំផុតក្នុងតំបន់ដែល ៣៦ ភាគរយ នៃប្រជាជនសរុប ១៣,៤ លាន នាក់ កំពុងរស់នៅ ក្រោមបន្ទាត់ក្រីក្រ និង ២០ ភាគរយទៀតជាក្រុមគ្រួសារដែលមានស្រ្តីមេម៉ាយជាអ្នកដឹកនាំ។

បន្ទាប់ពីមានសន្ធិសញ្ញាទីក្រុងសីណៃវឆ្នាំ ១៩៩១ មូលនិធិជំនួយសំរាប់កសាងប្រទេស ឡើង វិញចាប់ផ្តើមដំណើរការ។ ក្នុងបរិបទមួយបន្ទាប់ពីសង្គ្រាមស៊ីវិលបានបញ្ចប់ មីក្រូហិរញ្ញវត្ថុ ជាផ្នែក មួយដែលអ្នកផ្តល់ជំនួយ ទទួលបានការជោគជ័យខ្ពស់ក្នុងទំនាក់ទំនងយ៉ាងជិតស្និទ្ធិជា មួយវិស័យ ឯកជន សង្គមស៊ីវិល និងរាជរដ្ឋាភិបាល។ ការជោគជ័យជាបន្តបន្ទាប់ក្នុងវិស័យ ពាណិជ្ជកម្មក្នុង ស្រុកនេះជាគំរូមួយ ដើម្បីបញ្ជាក់ឲ្យឃើញពីអភិបាលកិច្ចល្អ មានតម្លាភាព និងការសហប្រតិបត្តិការ ខ្ពស់។ ដូចនេះ វិស័យពាណិជ្ជកម្មនៅកម្ពុជាបានកំពុងទាក់ទាញ វិនិយោគទុក បរទេសឲ្យមកវិនិ យោគកាន់តែច្រើនដែលនេះជាគន្លឹះដ៏សំខាន់ក្នុងការផ្លាស់ប្តូរ ផ្នត់គំនិត និង បរិយាកាសវិនិយោគថ្មី ក្នុងប្រទេស។

ជាមួយនឹងការរីកចំរើន និងការអភិវឌ្ឍន៍យ៉ាងខ្លាំងក្លា ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និង វប្បធមិសង្គមរបស់កម្ពុជា និងក្នុងតំបន់អាស៊ាន បានញុំាំងឲ្យប្រទេសកម្ពុជាអនុវត្តគោលនយោ បាយឈរលើគោលការណ៍នីតិរដ្ឋ ដែលនេះធ្វើឲ្យប្រជាពលរដ្ឋអ្នកនយោបាយ និងពាណិជ្ជករត្រូវ អនុវត្តតាមគោលការណ៍ច្បាប់។ ដូចនេះការធ្វើពាណិជ្ជកម្ម ដែលមិនស្របច្បាប់ បានជួបបញ្ហាជា ច្រើន និង ប្រឈមមុខ នឹងការផ្អាកសកម្មភាពពាណិជ្ជកម្មទាំងនោះ។ ដោយឡែកនាពេល បច្ចុប្បន្ន សហគ្រិនបានយល់ច្បាស់ក្នុងការធ្វើពាណិជ្ជកម្មស្របច្បាប់ ដើម្បីឲ្យដំណើរការពាណិជ្ជកម្មរបស់ពួក គេមានភាពរលូនទៅមុខ និង ទទួលបានជោគជ័យក្នុងពេលអនាគត។ ម្យ៉ាងវិញទៀតក្នុងការបើក

អាជីវកម្ម ឬ ក្នុងការធ្វើពាណិជ្ជកម្ម ឬ ក្នុងការបង្កើតនូវអង្គការសមាគមនានា គឺសុទ្ធតែជាសិទ្ធិរបស់របស់នីតិបុគ្គលដែលបានកំណត់នៅក្នុងច្បាប់នានាដែលមានជាធរមានក្នុងប្រទេសកម្ពុជា។

## ២- ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយសារតែក្នុងជីវភាពរបស់ប្រជាជនបច្ចុប្បន្នកាន់តែមានភាពរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃគួរអោយកត់សំគាល់ ដែលធ្វើឲ្យសកម្មភាពអាជីវកម្មកាន់តែមានភាពរីកចម្រើនច្រើនឡើងៗដែរ ព្រោះថាសកម្មភាពអាជីវកម្មធ្វើឲ្យជីវភាពរបស់ប្រជាជនពីមួយថ្ងៃទៅមួយថ្ងៃកាន់តែប្រសើរឡើងជាលំដាប់។ ហេតុនេះហើយយើងចង់ដឹងថាតើអ្នកដែលប្រកបរបរអាជីវកម្មនោះត្រូវបានគេចាត់ទុកជាអ្វី? ហើយតើត្រូវធ្វើដូចម្តេចដើម្បីឲ្យអាជីវកម្មនោះមានលក្ខណៈស្របច្បាប់? ហើយនឹងត្រូវធ្វើអ្វីខ្លះដើម្បីក្លាយជាខ្លួនទៅជាពាណិជ្ជករដែលមានលក្ខណៈជានីតិបុគ្គល? ហើយថាតើនីតិវិធីនៃការចុះបញ្ជីនីតិបុគ្គលនៅកម្ពុជាមានលក្ខណៈយ៉ាងដូចម្តេច? ដូច្នេះនឹងបានជ្រាបច្បាស់ខាង ក្រុមរបស់យើងខ្ញុំនឹងធ្វើការបកស្រាយខាងក្រោមនេះ។

## ៣- គម្មវត្ថុនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះផ្តោត សំខាន់ទៅលើដំណើរការនៃការចុះបញ្ជីជានីតិបុគ្គល។ ដូចនេះគោលបំណងសំខាន់ គឺដើម្បីស្វែងយល់ពីដំណើរការបង្កើត ក្រុមហ៊ុនពាណិជ្ជកម្ម ឬ អង្គការសមាគមនៅកម្ពុជា ដោយសង្កត់ធ្ងន់ទៅលើ៖

- ការជ្រើសរើសទម្រង់ក្រុមហ៊ុន ឬ អង្គការសមាគម។
- គោលការណ៍ និងនីតិវិធីក្នុងការចុះបញ្ជីក្រុមហ៊ុន។
- សិក្សាលើស្ថាប័នពាក់ពន្ធ័ នឹងការបង្កើតអាជីវកម្ម ។

ការស្រាវជ្រាវនេះផងដែរ គឺធ្វើការវិភាគទៅលើចំណុចទាំងឡាយដូចជាគុណសម្បត្តិ និងគុណវិបត្តិនៃការចុះបញ្ជីជានីតិបុគ្គល និង ចំណុចផ្សេងៗទៀត ព្រមទាំងធ្វើសេចក្តីសន្និដ្ឋានទៅលើគ្រប់ចំណុច និងផ្តល់អនុសាសន៍ទៅលើចំណុចមួយចំនួនផងដែរ។

## ៤- សារៈសំខាន់នៃការស្រាវជ្រាវ

នីតិបុគ្គល គឺជាចង្កោមមនុស្សមួយក្រុមដែលគេបានបង្កើតឡើង បានចុះបញ្ជីដែលមានទុនត្រឹមត្រូវ គេមាននាមករណ៍របស់គេដាច់ដោយឡែក មានអាជ្ញាធរទទួលស្គាល់ ហើយក្នុងនោះតើគេ

បង្កើតឡើងនោះ ដើម្បីធ្វើសកម្មភាពអ្វី ក្នុងកំឡុងពេលណា ពីព្រោះនៅពេលដែលចូលក្នុងទំនាក់ទំនងសង្គម តើអ្នកណាដែលជាតំណាងដើម្បីឱ្យមានលទ្ធភាពថា មនុស្សដទៃនោះដែលមានទំនាក់ទំនងជាមួយគ្នា។ ដូចនេះពេលដែលយើងមិនបានបែងចែកផ្នែកនេះឱ្យមានទំនាក់ទំនងច្បាស់លាស់ ហើយនៅពេលដែលមានរឿងរ៉ាវកើតឡើងនោះ ពីព្រោះនីតិបុគ្គល គឺជាចង្កោមមនុស្ស ហើយចង្កោមមនុស្សនោះមានអង្គការចាត់តាំងត្រឹមត្រូវ ពេលនោះការចុះហត្ថលេខាធ្វើកិច្ចការដទៃទៀតកើតឡើង ហើយអ្នកនោះឯងជាតំណាងឱ្យនីតិបុគ្គលតែទី១ ត្រូវតែតំណាងឱ្យរូបវន្តបុគ្គលខ្លួនឯង។

## II- និយមន័យ

**នីតិបុគ្គល** គឺជាក្រុមមនុស្សដែលច្បាប់ទទួលស្គាល់ថាជាបុគ្គលដែរតែដទៃពីសមាជិកនៃខ្លួន[1] ។ ឧទាហរណ៍៖ ពុទ្ធិកសមាគមជានីតិបុគ្គល ក្រុមហ៊ុនធ្វើស្ករ ក៏ជានីតិបុគ្គលដែរ។

**នីតិបុគ្គល** គឺជាក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច[2]។ ឧទាហរណ៍៖ សមាគម ក្រុមហ៊ុនជាដើម។

**នីតិបុគ្គល** គឺជាក្រុមមនុស្ស ឬ មូលនីធិដែលមានបុគ្គលភាពគតិយុត្ត ហើយ ជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ច[3]។

**នីតិបុគ្គល** គឺជាចង្កោមមនុស្សមួយក្រុមដែលមានចុះបញ្ជី មានអាជ្ញាធរទទួលស្គាល់ បង្កើតឡើងដើម្បីធ្វើសកម្មភាពអ្វីមួយ[4]។

**នីតិបុគ្គល** គឺសំដៅដល់សហគ្រាស ឬអង្គការនានាដែលប្រកបអាជីកម្ម ទោះបីជាបាន ឬមិនទាន់ទទួលបានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្តី។ ពាក្យ នីតិបុគ្គល រួមបញ្ចូលផងដែរនូវស្ថាប័នរដ្ឋាភិបាល អង្គការសាសនា អង្គការសប្បុរសធម៌ ឬអង្គការមិនស្វែងរកចំណេញ។ ចំពោះបុគ្គលអនិវាសនជន ពាក្យ នីតិបុគ្គល សំដៅដល់គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពាក្យ នីតិបុគ្គល ពុំរាប់បញ្ចូលទេនូវក្រុមហ៊ុនអាជីវកម្ម ឬ សហគ្រាសឯកបុគ្គល[5]។ អង្គភាពនីតិបុគ្គលដែលបង្កើតឡើង ឬ រៀបចំឡើងស្របតាមច្បាប់នៃប្រទេសជា

[1] សទ្ទានុក្រម ច្បាប់ភូមិបាលឆ្នាំ២០០១។
[2] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ រដ្ឋប្បវេណី ២០០៦។
[3] មាត្រា៥ នៃច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ ឆ្នាំ២០១០។
[4] មេរៀនរដ្ឋប្បវេណីរបស់ឯកឧត្តម យូ ប៊ុនឡេង ដែលរៀបចំ និង កត់ត្រាដោយ វេជ្ជ.ម៉ម ដាត្លារ៉ា។
[5] មាត្រា៣ថ្មី នៃច្បាប់ស្តីពី វិសោធនកម្មនៃច្បាបស់សារពើពន្ធ ឆ្នាំ២០០៣។

សមាជិក ទោះជាដើម្បីរកផលចំណេញ ឬមិនរកផលចំណេញ កាន់កាប់ដោយឯកជន ឬដោយរដ្ឋ រួមទាំងសាជីវកម្មដៃគូរសហគ្រាសចម្រុះកម្មសិទ្ធិឯកជនឬសមាគម[6]។

## III- ប្រភេទនៃនីតិបុគ្គល

នីតិបុគ្គលមានពីរប្រភេទ គឺនីតិបុគ្គលឯកជន និង នីតិបុគ្គលសាធារណៈ ។ នីតិបុគ្គលសាធារណៈមានពីរប្រភេទ គឺនីតិបុគ្គលសាធារណៈដែនដី និង នីតិបុគ្គលសាធារណៈបច្ចេកទេស (Technical Legal Entity) ។ នីតិបុគ្គលសាធារណៈដែនដី សំដៅទៅលើសមូហភាព ដែនដីដែលមានមនុស្សមួយក្រុមរស់នៅ រួមគ្នាលើទឹកដីជាមួយគ្នាដូចជារដ្ឋ "ជាដើម" រដ្ឋជាមួយសមូហភាពដែនដីមួយសម្រាប់សហគមជាតិទាំងមូល ។ រដ្ឋតាមន័យគតិយុត្ត គឺជានីតិបុគ្គល ដែលមានអធិបតេយ្យ ។ រដ្ឋនីមួយៗត្រូវមានលក្ខខណ្ឌនៃធាតុផ្សំទាំងនេះ គឺថារដ្ឋត្រូវមានប្រជាពលរដ្ឋជាក់លាក់រដ្ឋាភិបាលមួយជាអង្គការនយោបាយរបស់រដ្ឋ និងទឹកដីមួយដែលកំណត់ ច្បាស់លាស់ ។

ដើម្បីអោយរដ្ឋមួយអាចមាន អត្ថិភាពទៅបាន ទាល់តែវាមានជាដាច់ខាត នូវធាតុផ្សំទាំងបីនេះ និង មានអធិបតេយ្យភាព។ ចំណែកឯនីតិបុគ្គលសាធារណៈបច្ចេកទេស វិញជានីតិបុគ្គលសាធារណៈដែលត្រូវបានបង្កើតឡើង ដើម្បីបំពេញការត្រូវការ ជាផលប្រយោជន៍សាធារណៈណាមួយច្បាស់ដោយឡែក ដូចជាដើម្បីគ្រប់គ្រងមន្ទីរពេទ្យ សាកលវិទ្យាល័យ អគ្គីសនី ឬ ការកំចាត់មីនជាដើមជាដើម ។ នីតិបុគ្គលនេះ ជាអង្គភាព មួយដែលបង្កើតឡើងដោយច្បាប់ មានទ្រព្យសម្បត្តិ និង ថវិកាផ្ទាល់ខ្លួន និង ស្វ័យភាពក្នុងការគ្រប់គ្រង មានឯកទេសកម្មព្រមទាំងស្ថិតនៅក្រោម អាណាព្យាបាលរបស់រដ្ឋ ឬ សមូហភាពដែនដី ។ នីតិបុគ្គលឯកជន ជាបណ្តុំនៃរូបវន្តបុគ្គល ដែលបង្កើតឡើងដោយច្បាប់ ក្នុងគោលដៅស្វែង រកផលចំណេញ និង បម្រើផលប្រយោជន៍រូបវន្តបុគ្គលដែលជាសមាជិករបស់ខ្លួន ។ ឧទាហរណ៍ ដូចជា ក្រុមហ៊ុន សមាគម សហជីព អង្គការក្រៅរដ្ឋាភិបាល ឬ អង្គការអន្តរជាតិផ្សេងៗ ។ល។

### ១- នីតិបុគ្គលសាធារណៈ

ដើម្បីយល់ច្បាស់ពីអត្ថន័យនៃពាក្យ"នីតិបុគ្គលសាធារណៈ" យើងត្រូវយល់ន័យនៃពាក្យសំខាន់មួយចំនួនសិន ដូចជា "នីតិ និង នីតិបុគ្គល"។ នីតិ គឺជាបណ្តាវិធានទាំងឡាយ ដែលគ្រប់គ្រងទៅលើជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្ស ដែលរស់នៅក្នុងសង្គមហើយដែលត្រូវដាក់ទណ្ឌកម្មដោយអំណាចសាធារណៈ។ នីតិ គឺជាបណ្តាវិធានទាំងឡាយណាដែលអនុម័តឡើងដោយនីតិបញ្ញត្តិ

[6] មាត្រា១ នៃច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីតំបន់វិនិយោគ អាស៊ាន ប្រកាសឱ្យប្រើ ២៨ តុលា ០៥ ។

ក្នុងគោលបំណងដើម្បីបម្រើផលប្រយោជន៍សាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ទំនៀមទម្លាប់ល្អរបស់ជាតិ និង មានការដាក់ទណ្ឌកម្មក្នុងករណីមានការរំលោភបំពានវា។ តាមន័យនៃច្បាប់ បុគ្គលមានពីរ យ៉ាងគឺ រូបវ័ន្តបុគ្គល (Natural Person) និង នីតិបុគ្គល (Legal Entity) រូបវ័ន្តបុគ្គលសំដៅទៅលើបុគ្គលដែលមានសាច់មានឈាម អាចមានជីវិត រស់នៅបាន និង មានបុគ្គលភាពគតិយុត្ត។ រូបវន្តបុគ្គលត្រូវតែជាមនុស្ស មិនមែនសត្វតិរច្ឆាន ឡើយ។ នីតិបុគ្គល គឺជាបុគ្គលអរូប ដែលច្បាប់និម្មិតបង្កើតមកសម្រាប់បំរើគោលដៅ និង ផលប្រយោជន៍រួមរបស់បុគ្គលមួយក្រុម ឬ របស់សង្គមមួយ។ ដូច្នេះបើគ្មានច្បាប់ចែងថា ជានីតិបុគ្គលទេបុគ្គលមួយក្រុមនោះគ្រាន់តែក្រុមបុគ្គលមួយតែប៉ុណ្ណោះ។ កាលណាបាន លក្ខណៈជានីតិបុគ្គលតាមផ្លូវច្បាប់ហើយ បុគ្គលភាពគតិយុត្តក៏កើតមានឡើងដែរ។ សរុបមកនីតិបុគ្គលសាធារណៈគឺជាបុគ្គលអរូបដែលច្បាប់ បង្កើតមកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ និង សេវាកម្មសាធារណៈ ដោយមិនស្វែងរកផលចំណេញ ។

## ២- នីតិបុគ្គលឯកជន

នីតិបុគ្គលឯកជន គេអាចធ្វើចំណាត់ប្រភេទវាតាមប្រពៃណីនៃទម្លាប់ដោយគ្រាន់តែផ្អែកលើភាពខុសប្លែកគ្នា រវាងកម្មវត្ថុស្វែងរកប្រាក់ចំនេញ និងមិនស្វែងរកប្រាក់ចំនេញ[7]។

ចំពោះគោលដៅក្នុងការស្វែងរកប្រាក់ចំណេញ គឺជាប្រភេទនីតិបុគ្គលក្រុមហ៊ុនហើយមិនស្វែងរកប្រាក់ចំនេញគឺជាប្រភេទសមាគមន៍។ ចំពោះប្រភេទក្រុមហ៊ុន ក៏ចែកលម្អិតរវាងក្រុមហ៊ុនពាណិជ្ជកម្ម និង ក្រុមហ៊ុនរដ្ឋប្បវេណី។ ក្រុមហ៊ុនពាណិជ្ជកម្ម មានជាអាទិ៍ ក្រុមហ៊ុនអនាមិក(ក្រុមហ៊ុនមហាជន ឬ ក្រុមហ៊ុនទទួលខុសត្រូវគ្មានកម្រិត) ចំណែកក្រុមហ៊ុនរដ្ឋប្បវេណីសំដៅទៅដល់ប្រភេទក្រុមហ៊ុន ដែលមានសកម្មភាពតាមវិស័យច្បាស់លាស់ ជាអាទិ៍ក្រុមហ៊ុនប្បវេណីអចលនទ្រព្យ ក្នុងនោះមានក្រុមហ៊ុនសាងសង់ ក្រុមហ៊ុនអចលនទ្រព្យខាងកសិកម្ម ឬព្រៃឈើ....។

## ២.១- នីតិបុគ្គលមូលនិធិ[8]

ក- នីតិបុគ្គលមូលនិធិ អាចត្រូវបានបង្កើតឡើង ដោយធ្វើលក្ខន្តិកៈ និង ទទួលការ អនុញ្ញាតពីសំណាក់ស្ថាប័នដែលមានសមត្ថកិច្ច ត្រួតពិនិត្យ លុះត្រាតែមានគោលបំណង ដើម្បីផលប្រយោជន៍សាធារណៈ ។

[7] ការធ្វើចំណាត់ប្រភេទមួយបែបទៀតមានលក្ខណៈទូទៅ គឺប្រភេទនៃបណ្តុំក្រុមមនុស្សនិងបណ្តុំទ្រព្យសម្បត្តិ (Marty & Raynaud, op. cit. n° ៨២២-Carbonnier, op. cit. n° ៧៦, p.396-Teyssié, op. cit. . n° ៣៩៣.....-Weill & Terré, op. cit. . n° ១៦២។ ចំពោះប្រភេទចុងក្រោយ គឺសំដៅទៅលើនីតិបុគ្គលជាមូលនិធិ ដែលបានមកពីការចូលរួមដោយពេញចិត្ត នូវទ្រព្យសម្បត្តិ ឬប្រភពក្នុងការបង្កើតជាស្នាដៃមួយ ដើម្បីផលប្រយោជន៍រួមឬទូទៅ។ ប៉ុន្តែបុគ្គលភាពគតិយុត្តនៃមូលនិធិ គឺផ្អែកទៅលើការបង្កើតជាសមាគមន៍ពោលគឺមានក្រុមមនុស្ស។

[8] មាត្រា១១០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ខ- លក្ខន្តិកៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវសរសេរនូវ ចំណុច ដូចខាងក្រោម ៖

-គោលបំណង ។

-នាមករណ៍ ។

-ទីតាំងនៃទីស្នាក់ការកណ្តាល ។

-បញ្ញត្តិស្តីពីចំនួនទឹកប្រាក់សរុបនៃទ្រព្យសម្បត្តិជាមូលដ្ឋាន និង ទ្រព្យធន សកម្ម ។ ក្នុងករណីដែលមានវិភាគទានជាវត្ថុក្រៅពីប្រាក់ ត្រូវសរសេរនូវឈ្មោះ និង តម្លៃនៃទ្រព្យសម្បត្តិនោះ ឬ ក្នុងករណី ដែលបុគ្គលណាបានសន្យាថា នឹងធ្វើអនុប្បទាន ទ្រព្យសម្បត្តិណា មួយក្រោយពីការបង្កើតនីតិបុគ្គល ត្រូវសរសេរនូវតម្លៃនៃទ្រព្យ សម្បត្តិ នោះ និង ឈ្មោះ ឬ នាមករណ៍របស់អនុប្បទាយី ឬ ត្រូវ សរសេរនូវចំនួនប្រាក់នៃ សោហ៊ុយសម្រាប់ការបង្កើតដែលនីតិបុគ្គល ត្រូវទទួលបន្ទុក ។

-ឆ្នាំអនុវត្តកិច្ចការ ។

-ចំណុចស្តីពីអភិបាល អ្នកត្រួតពិនិត្យ និង អ្នកមានតួនាទីផ្សេង ទៀត ។

-ចំណុចស្តីពីគណនេយ្យ ។

-ចំណុចស្តីពីការរំលាយ ។

-ចំណុចស្តីពីការកែប្រែលក្ខន្តិកៈ ។

-វិធីផ្សព្វផ្សាយជាសាធារណៈ ។

គ- លក្ខន្តិកៈពុំមានអានុភាពឡើយ បើពុំបានទទួលសេចក្តីបញ្ជាក់ពី សារការី ។

ឃ- លក្ខន្តិកៈត្រូវរក្សាទុកនៅទីតាំងនៃទីស្នាក់ការកណ្តាល និង ទីស្នាក់ការសាខា ។

ចំនួនទឹកប្រាក់អប្បបរមានៃទ្រព្យសម្បត្តិជាមូលដ្ឋាននីតិបុគ្គលមូលនិធិ ត្រូវមានទ្រព្យសម្បត្តិជាមូលដ្ឋានដែលមានតម្លៃ មិនតិចជាង ២០០.០០០.០០០ (ពីររយលាន) រៀល [9]។

ការបំពេញបង្រ្គប់លក្ខន្តិកៈក្នុងករណីដែលអ្នកបង្កើតនីតិបុគ្គលមូលនិធិបានទទួលមរណភាពដោយមិនទាន់ បានកំណត់នាមករណ៍ ទីស្នាក់ការ ឬ វិធីចាត់តាំង និង បញ្ឈប់អភិបាលទេ តុលាការអាចកំណត់ចំណុចនេះតាមពាក្យសុំ របស់អ្នកដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ ដោយ តំណាងអយ្យការបាន [10]។

[9] មាត្រា១១១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[10] មាត្រា១១២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

## ២.២- ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ជាទូទៅក្រុមហ៊ុនប្រភេទនេះ មានលក្ខណៈដូចជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមាន កំរិត ប៉ុន្តែលក្ខណៈដែលខុសគ្នា គឺក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវបានអនុញ្ញាត ដោយច្បាប់ដើម្បីបោះមូលប័ត្ររបស់ខ្លួនជាសាធារណៈ។ គោលបំណងនៃការអនុញ្ញាតឲ្យបោះ បណ្ណ័ភាគហ៊ុនរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និង ការកម្រិតទទួលខុសត្រូវ របស់ម្ចាស់ហ៊ុន ត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់ និង ដាក់លាក់ក្នុងលក្ខន្តិកៈក្រុមហ៊ុន។

## ២.៣- ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវបានគ្រប់គ្រងដោយអ្នកគ្រប់គ្រង និង អភិបាលនឹងផ្ដល់មូលនិធិដោយដើមទុនដែលផ្ដល់ឲ្យដោយម្ចាស់ហ៊ុម។ ក្រុមហ៊ុនផ្ដល់នូវគម្រោង ការងារសម្រាប់អាជីវកម្ម ដើម្បីធ្វើជាម្ចាស់ទ្រព្យសម្បត្តិចុះកិច្ចសន្យា និង ភ្ជាប់កាតព្វកិច្ចតាមផ្លូវ ច្បាប់ ដើម្បីជៀសវាងការដាក់ទ្រព្យសកម្មរបស់ម្ចាស់ហ៊ុនក្នុង ហានិយភ័យ។ ក្រុមហ៊ុនត្រូវ ជាប់ពន្ធលើទ្រព្យសម្បត្តិ ប្រាក់ចំណូលការលក់ និងពន្ធ ផ្សេងៗទៀតដែលអាចមាន។

ក្រុមហ៊ុនត្រូវបានបង្កើតឡើងតាមរយៈដំណើរការមួយដែលតម្រូវឲ្យដាក់លក្ខន្តិកៈ និងបទ បញ្ញាផ្ទៃក្នុងរបស់ ក្រុមហ៊ុនទៅកាន់ក្រសួងពាណិជ្ជកម្ម។ ម្ចាស់ហ៊ុនទទួលខុស ត្រូវត្រឹម កម្រិតនៃចំនួនទឹកប្រាក់ ដែលនៅសល់នៃតម្លៃចារឹកលើបណ្ណ័នៃភាគហ៊ុនរបស់គេ។ ក្រុមហ៊ុន ឯកជនទទួល ខុសត្រូវមានកម្រិត គឺជាទម្រង់អាជីវកម្មតាមផ្លូវច្បាប់ដែលពេញនិយមបំផុត។ នៅ ពេលដែល ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតត្រូវបានបង្កើតតាមផ្លូវច្បាប់ទ្រព្យសម្បត្តិ របស់វាត្រូវមានលក្ខណៈដាច់ដោយឡែកពីទ្រព្យសម្បត្តិម្ចាស់ភាគហ៊ុន ហើយក្រុមហ៊ុននេះត្រូវចុះកិច្ចសន្យា នឹង ប្ដឹងគេ ឬត្រូវគេប្ដឹងក្នុងនាម របស់ក្រុមហ៊ុន។ ប្រភេទនៃទម្រង់ក្រុមហ៊ុននេះនឹងដំណើរការ រហូត ទោះបីជាម្ចាស់ហ៊ុនទាំងនោះទទួលមរណភាពក៏ដោយ លុះត្រាតែក្រុមហ៊ុនត្រូវបាន រំលាយ ស្របច្បាប់តាម ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម។ ដើម្បីបង្កើតក្រុមហ៊ុនទទួលខុសត្រូវមាន កម្រិត គឺ មានភាពស្មុគស្មាញនិងចំណាយច្រើនជាងទម្រង់ក្រុមហ៊ុនផ្សេងៗទៀត។

ជាទូទៅ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវមានសមាជិកចាប់ពី ២ នាក់ រហូតដល់ ៣០នាក់។ ប៉ុន្តែប្រសិនបើមានបុគ្គលតែម្នាក់កាន់កាប់ភាគហ៊ុនទាំងអស់នោះ គេអាច ចុះបញ្ជីជាសហគ្រា ឯកបុគ្គលទទួលខុសត្រូវមានកម្រិត។ ក្រុមហ៊ុនឯកជនទទួលខុសត្រូវ មានកម្រិតមិនអនុញ្ញាតឲ្យ លក់ភាគហ៊ុន ឬមូលប័ត្រដទៃទៀត ជាសាធារណៈបានឡើយ ប៉ុន្តែអាចផ្ទេរ ឬប្រទានទៅឲ្យ សមាជិកហ៊ុន សមាជិកគ្រួសារ និងអ្នកគ្រប់គ្រងបាន។

## ២.៤- នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត[11]

ក- ដើម្បីបង្កើតនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត បុគ្គល ដែលមាន បំណងធ្វើជាសមាជិកត្រូវសហការគ្នា បង្កើតលក្ខន្តិកៈ ហើយចុះហត្ថលេខារៀងៗខ្លួន ។

ខ- លក្ខន្តិកៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរនូវ គ្រប់ចំណុចដូចខាងក្រោមនេះ ៖

-គោលបំណង ។

-នាមករណ៍ ។

-នាម និង លំនៅឋានរបស់សមាជិក ។

-ទីតាំងនៃទីស្នាក់ការកណ្តាល និង ទីស្នាក់ការសាខា ។

គ- លក្ខន្តិកៈពុំមានអានុភាពឡើយ បើពុំបានទទួលសេចក្តីបញ្ជាក់ ពីសារការី ។

ឃ- លក្ខន្តិកៈត្រូវរក្សាទុកនៅទីស្នាក់ការកណ្តាល និង ទីស្នាក់ការ សាខា ។

### ចំណុចដែលត្រូវចុះបញ្ជី និង អំឡុងពេលចុះបញ្ជី[12]

ក- ក្រៅពីចំណុចដែលបញ្ញត្តិនៅក្នុងមាត្រា ៥០ (ចំណុចដែលត្រូវ ចុះបញ្ជី) នៃក្រម នេះ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ត្រូវចុះបញ្ជីនៅទីតាំងនៃទីស្នាក់ការ កណ្តាល នូវគ្រប់ចំណុច ដូច កំណត់ខាងក្រោមនេះ ៖

- នាមសមាជិកដែលធ្វើតំណាងឱ្យនីតិបុគ្គល ក្នុងករណីដែលមាន សមាជិកខ្លះ ពុំធ្វើជាតំណាងឱ្យនីតិបុគ្គលនោះ ។

- សេចក្តីកំណត់ ក្នុងករណីដែលមានការកំណត់ថា សមាជិកច្រើន រូបធ្វើ តំណាងឱ្យនីតិបុគ្គលនោះ ។

ខ- នៅទីតាំងនៃទីស្នាក់ការសាខា ការចុះបញ្ជីដែលបានកំណត់នៅ ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើង ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតពីថ្ងៃដែលបានចុះបញ្ជី តាមបញ្ញត្តិនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

## ២.៥- នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត[13]

ក- ដើម្បីបង្កើតនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត បុគ្គលដែលមាន បំណងធ្វើជាសមាជិកត្រូវសហការគ្នាបង្កើត លក្ខន្តិកៈ ហើយចុះហត្ថលេខារៀងៗខ្លួន ។

[11] មាត្រា១០១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
[12] មាត្រា១០២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
[13] មាត្រា៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ខ- លក្ខន្តិកៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរនូវ គ្រប់ចំណុចដូចខាងក្រោម ៖

-គោលបំណង ។

-នាមករណ៍ ។

-ទីតាំងនៃទីស្នាក់ការកណ្តាល ។

-បញ្ញត្តិស្តីពីចំនួនទឹកប្រាក់សរុបនៃទ្រព្យសម្បត្តិជាមូលដ្ឋានដែលត្រូវធានា ក្នុងនាមជានីតិបុគ្គល និង ទ្រព្យធនសកម្ម ។ ក្នុងករណីដែលមានវិភាគទានជាវត្ថុក្រៅពី ប្រាក់ ត្រូវសរសេរនូវឈ្មោះ ឬ នាមករណ៍របស់បុគ្គលធ្វើវិភាគទានជាវត្ថុក្រៅពីប្រាក់ ឈ្មោះ និង តម្លៃនៃទ្រព្យសម្បត្តិនោះ ឬ ក្នុងករណីដែលបុគ្គល ណាម្នាក់បានសន្យាថា នឹងធ្វើអនុប្បទានទ្រព្យសម្បត្តិណាមួយ ក្រោយពីការបង្កើតនីតិបុគ្គល ត្រូវសរសេរនូវតម្លៃ នៃទ្រព្យ សម្បត្តិនោះ និង ឈ្មោះ ឬ នាមករណ៍របស់អនុប្បទាយី ឬ ត្រូវ សរសេរនូវចំនួន ប្រាក់នៃសោហ៊ុយដែលចំណាយ ក្នុងការ បង្កើតនីតិបុគ្គល ហើយដែលនីតិបុគ្គលត្រូវទទួល បន្ទុក ។

-ឆ្នាំអនុវត្តកិច្ចការ ។

-ចំណុចស្តីពីអភិបាល អ្នកត្រួតពិនិត្យ និង អ្នកមានតួនាទីផ្សេង ទៀត ។

-បញ្ញត្តិស្តីពីការទទួល និង ការបាត់បង់សមាជិកភាព ។

-ចំណុចស្តីពីគណនេយ្យ ។

-ចំណុចស្តីពីការរំលាយ ។

-ចំណុចស្តីពីការកែប្រែលក្ខន្តិកៈ ។

-វិធីផ្សព្វផ្សាយជាសាធារណៈ ។

គ- លក្ខន្តិកៈពុំមានអានុភាពឡើយ បើពុំបានទទួលសេចក្តីបញ្ជាក់ពី សារការីទេ ។

ឃ- លក្ខន្តិកៈត្រូវរក្សាទុកនៅទីស្នាក់ការកណ្តាល និង ទីស្នាក់ការ សាខា ។

### ចំនួនទឹកប្រាក់អប្បបរមានៃទ្រព្យសម្បត្តិជាមូលដ្ឋាន[14]

នីតិបុគ្គលទទួលខុសត្រូវមានកម្រិត ត្រូវមានទ្រព្យសម្បត្តិជាមូលដ្ឋានដែលមាន តម្លៃមិនតិចជាង ២០.០០០.០០០ (ម្ភៃលាន) រៀល ។

[14] មាត្រា៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

## IV- គោលការណ៍នៃការបង្កើតនីតិបុគ្គល

ក- ក្រុមដែលមានសមាជិក ហើយត្រូវបានប្រគល់នូវឋានៈជា ប្រធាននៃសិទ្ធិ និង កាតព្វកិច្ច ដោយឯករាជ្យ ហៅថា នីតិបុគ្គលសាជីវកម្ម ចំណែកឯ ទ្រព្យសម្បត្តិវិភាគទានដែលត្រូវ បានប្រគល់នូវឋានៈជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ច ដោយឯករាជ្យ ហៅថា នីតិបុគ្គលមូលនិធិ។

ខ- នៅក្នុងក្រុមនេះ នីតិបុគ្គលដែលគ្មានគោលបំណងទាញយកចំណេញ ហៅថា នីតិបុគ្គលមិនយកចំណេញ ចំណែកឯនីតិបុគ្គលដែលទាញយក ចំណេញ ហៅថា នីតិបុគ្គល យកចំណេញ។ នៅក្នុងចំណោម នីតិបុគ្គលមិនយកចំណេញ នីតិបុគ្គលដែលមានគោលបំណង ពិសេសដើម្បីបម្រើប្រយោជន៍សាធារណៈ ហៅថា នីតិបុគ្គលបម្រើ ប្រយោជន៍ សាធារណៈ ។

គ- នៅក្នុងក្រុមនេះ នីតិបុគ្គលសាជីវកម្មដែលសមាជិកទទួលខុសត្រូវនូវកាតព្វកិច្ច របស់ នីតិបុគ្គល តាមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានធ្វើវិភាគទាន ហៅថា នីតិបុគ្គល សាជីវកម្មទទួលខុសត្រូវមានកម្រិត ចំណែក ឯនីតិបុគ្គលសាជីវកម្មដែលសមាជិកទទួលខុស ត្រូវនូវកាតព្វកិច្ច របស់នីតិបុគ្គល ដោយយកទ្រព្យសម្បត្តិទូទៅរបស់ខ្លួន ហៅថា នីតិបុគ្គល សាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

ឃ- នីតិបុគ្គលមិនអាចធ្វើជាសមាជិកដែលទទួលខុសត្រូវគ្មានកម្រិតរបស់នីតិបុគ្គល សាជីវកម្មផ្សេងទៀតបានឡើយ ។

ង- នីតិបុគ្គលមិនយកចំណេញ អាចបង្កើតឡើងតាមក្រុមនេះ ឬ បទដ្ឋានគតិយុត្ត នៃច្បាប់ផ្សេងៗទៀតបាន ។

ច- នីតិបុគ្គលទាញយកចំណេញ អាចបង្កើតឡើងបានដោយយោងទៅតាមបញ្ញត្តិ នៃច្បាប់ផ្សេងៗទៀត ។

### ១- ការចុះបញ្ជីនៃការបង្កើត

ការចុះបញ្ជីនៃការបង្កើត និង ពេលវេលាកំណើតនៃនីតិបុគ្គលនីតិបុគ្គលត្រូវបានបង្កើតឡើងដោយការចុះបញ្ជីនៅកន្លែង ដែលមានទីតាំងនៃទី ស្នាក់ការកណ្តាលរបស់នីតិបុគ្គលនោះ[15]។

[15] មាត្រា៤៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

### ❖ ចំណុចដែលត្រូវចុះបញ្ជី[16]

ក- ដើម្បីចុះបញ្ជីនីតិបុគ្គល ត្រូវចុះនូវចំណុចនីមួយៗដូចបាន កំណត់ខាងក្រោមនេះ៖

- គោលបំណង
- នាមករណ៍
- ទីស្នាក់ការកណ្តាល និង ទីស្នាក់ការសាខា។
- មូលហេតុនៃការរំលាយ បើបានកំណត់មូលហេតុនោះ នៅក្នុង លក្ខន្តិកៈ ។
- ឈ្មោះ ឬ នាមករណ៍ និង លំនៅឋានរបស់អភិបាល និង អ្នកត្រួត ពិនិត្យ ។ ប៉ុន្តែ ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ត្រូវចុះឈ្មោះ និង លំនៅឋាន របស់សមាជិក។
- ឈ្មោះរបស់អភិបាលដែលត្រូវធ្វើជាតំណាងនីតិបុគ្គល បើមានជនដែលជា អភិបាល តែមិនតំណាងឱ្យនីតិបុគ្គលនោះ ។
- សេចក្តីកំណត់អំពីសហតំណាង ដែលកំណត់ថា អភិបាលច្រើន នាក់ធ្វើ តំណាងឱ្យ នីតិបុគ្គលដោយរួមគ្នា ប្រសិនបើមាន។

ខ- បើមានការផ្លាស់ប្តូរចំណុចណាមួយ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌ ទី ១ ខាងលើនេះ ត្រូវចុះបញ្ជី នៅទីតាំងនៃទីស្នាក់ការកណ្តាល ក្នុងអំឡុង ពេល ២ (ពីរ) សប្តាហ៍ និង នៅទីតាំងនៃទីស្នាក់ការផ្សេងទៀត ក្នុងអំឡុងពេល ៣ (បី) សប្តាហ៍ ។ នៅក្នុងអំឡុងពេលដែល មិន ទាន់បានចុះបញ្ជីទេការផ្លាស់ប្តូរពុំអាចតតាំងចំពោះតតិយជនបានឡើយ។

គ- ប្រសិនបើមានការចាត់ចែងជាបណ្តោះអាសន្ន ដែលផ្អាកការ អនុវត្តកិច្ចការ របស់អភិបាល ឬ ដែលជ្រើសតាំងបុគ្គលជំនួស អភិបាល ឬ បើមានការផ្លាស់ប្តូរ ឬ លុប ចោលនូវការចាត់ចែងជា បណ្តោះអាសន្ននោះ ត្រូវចុះបញ្ជីនៅទីតាំងនៃទីស្នាក់ការកណ្តាល និង ទីតាំងនៃទីស្នាក់ការផ្សេង ទៀត ។ នៅក្នុងករណីនេះ វាក្យខណ្ឌទី ២ នៃ កថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នា ផងដែរ ។

## ២- លំនៅដ្ឋាននៃនីតិបុគ្គល

លំនៅឋាននៃនីតិបុគ្គលនីតិបុគ្គលត្រូវមានលំនៅឋាន នៅទីតាំងនៃទីស្នាក់ការកណ្តាលរបស់ នីតិបុគ្គលនោះ[17] ។

[16] មាត្រា៥០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

## ២.១- ការចុះបញ្ជីអំពីការផ្លាស់ប្តូរទីតាំងទីស្នាក់ការ[18]

ក- នៅពេលដែលនីតិបុគ្គលផ្លាស់ប្តូរទីតាំងនៃទីស្នាក់ការកណ្តាល ត្រូវចុះបញ្ជីអំពី ការផ្លាស់ប្តូរនោះ នៅទីតាំងចាស់ ហើយត្រូវចុះបញ្ជី នូវចំណុចដែលបានកំណត់នៅក្នុង មាត្រា ៥០ (ចំណុចដែលត្រូវ ចុះបញ្ជី) នៃក្រមនេះ នៅទីតាំងថ្មី ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ។ នៅពេលដែលផ្លាស់ប្តូរទីតាំងទីស្នាក់ការឯទៀត ត្រូវចុះបញ្ជីអំពីការ ផ្លាស់ប្តូរ នោះ នៅទីតាំងចាស់ ក្នុងអំឡុងពេល ៣ (បី) សប្តាហ៍ ហើយត្រូវចុះបញ្ជីនូវចំណុចដែល បានកំណត់នៅក្នុងមាត្រា ៥០ (ចំណុចដែលត្រូវចុះបញ្ជី) នោះ នៅទីតាំងថ្មី ក្នុងអំឡុង ពេល ៤ (បួន) សប្តាហ៍ ។

ខ- ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ នៅក្នុង ករណីដែល ការផ្លាស់ប្តូរទីតាំងទីស្នាក់ការ ត្រូវបានធ្វើឡើង នៅក្នុង ដែនសមត្ថកិច្ចនៃការិយាល័យចុះ បញ្ជីដូចគ្នា នោះគ្រាន់តែចុះបញ្ជី អំពីការផ្លាស់ប្តូរទីតាំង ជាការគ្រប់គ្រាន់ហើយ ។

## ២.២- ការចុះបញ្ជីទីស្នាក់ការដែលបង្កើតថ្មី[19]

ក- ក្នុងករណីដែលនីតិបុគ្គលបានបង្កើតទីស្នាក់ការថ្មី ត្រូវចុះបញ្ជីនូវ ចំណុចដែល បានកំណត់នៅក្នុងមាត្រា ៥២ (ចំណុចដែលត្រូវ ចុះបញ្ជី) នៃក្រមនេះ ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ នៅទីតាំងនៃ ទីស្នាក់ការថ្មីនោះ ។

ខ- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចុះបញ្ជីអំពី ការបង្កើតទីស្នាក់ការថ្មី នៅទីតាំងនៃទីស្នាក់ការ កណ្តាល និង ទីតាំងនៃទីស្នាក់ការផ្សេង ទៀត ក្នុងអំឡុងពេល ៣ (បី) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានបង្កើតទីស្នាក់ការថ្មីនោះ ។

## ២.៣- ការគ្រប់គ្រង និង ការចាត់ចែងកិច្ចការនៃនីតិបុគ្គល

### ២.៣.១- បញ្ជីទ្រព្យសម្បត្តិ និង បញ្ជីរាយនាមសមាជិក

ក- នីតិបុគ្គលត្រូវធ្វើបញ្ជីទ្រព្យសម្បត្តិនៅពេលបង្កើត និង ក្នុងអំឡុង ពេល ៣ (បី) ខែ នៃដើមឆ្នាំអនុវត្តកិច្ចការ ហើយត្រូវទុកបញ្ជីនោះនៅ ក្នុងទីស្នាក់ការជានិច្ច ។

---

[17] មាត្រា៥១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[18] មាត្រា៥២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[19] មាត្រា៥៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ខ- នីតិបុគ្គលសាជីវកម្មត្រូវធ្វើបញ្ជីរាយនាមសមាជិក និង ទុកនៅ ទីស្នាក់ការជានិច្ច ហើយរាល់ពេលដែលមានការផ្លាស់ប្តូរសមាជិក ត្រូវកែតម្រូវបញ្ជីនោះ ។

### ២.៣.២- ចំនួន ការជ្រើសតាំង ការដកហូតតំណែង និង ភារកិច្ចនៃអភិបាល[20]

ក- នីតិបុគ្គលត្រូវមានអភិបាលដែលជាអង្គភាពមួយដើម្បីអនុវត្តកិច្ចការរបស់នីតិ-បុគ្គល។ ប៉ុន្តែ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មាន កម្រិត ពុំត្រូវមានអភិបាលឡើយ ។

ខ- អភិបាល អាចមានមួយរូប ឬ ច្រើនរូបបាន ។ ប៉ុន្តែ ចំពោះ នីតិបុគ្គលមូលនិធិ ត្រូវមានអភិបាលយ៉ាងតិច ៣ (បី) រូប ។

គ- ក្នុងករណីដែលមានអភិបាលច្រើនរូប កិច្ចការរបស់នីតិបុគ្គលត្រូវ សម្រេច ដោយសម្លេងភាគច្រើន បើគ្មានការកំណត់ពិសេសក្នុង លក្ខន្តិក:ទេ។

ឃ- អភិបាលត្រូវបានជ្រើសតាំងដោយលក្ខន្តិក: ឬ ដោយមហាសន្និបាតសមាជិក ។

ង- អភិបាលនៃនីតិបុគ្គលសាជីវកម្ម អាចត្រូវបានដកហូត តំណែងដោយសេចក្តី សម្រេចនៃមហាសន្និបាតសមាជិកបាន។

## V- ការចុះបញ្ជីពាណិជ្ជកម្មរបស់ពាណិជ្ជករជានីតិបុគ្គល

ពាណិជ្ជករទាំងរូបវន្តបុគ្គល និងនីតិបុគ្គលត្រូវធ្វើការផ្សព្វផ្សាយជាសាធារណ:តាមសារពត៌មានស្របច្បាប់ណាមួយដែលបានទទួលស្គាល់ ឬទស្សនាវដ្ដីប្រចាំតំបន់ដែលគ្រឹះស្ថានពាណិជ្ជកម្ម ឬក៏ទីស្នាក់ការក្រុមហ៊ុនតាំងនៅ គោលបំណងឲ្យសាធារណជនបានដឹងឮ និងការប្តឹងជំទាស់[21]។

ពាណិជ្ជករជារូបវន្តបុគ្គល និង នីតិបុគ្គល សាខាបុត្រសម្ព័ន្ធ ឬទីភ្នាក់ងាររបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។ យ៉ាងតិចបំផុត ១៥ថ្ងៃមុនពេលចាប់ផ្តើមបើកធ្វើពាណិជ្ជកម្មរបស់ខ្លួន[22]។

[20] មាត្រា៥៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
[21] នីតិពាណិជ្ជកម្មរៀបរៀងដោយសាស្ត្រាចារ្យ គង់ សាផន បោះពុម្ពលើកទី១ឆ្នាំ២០១២។
[22] នីតិពាណិជ្ជកម្មរៀបរៀងដោយសាស្ត្រាចារ្យ គង់ សាផន បោះពុម្ពលើកទី១ឆ្នាំ២០១២។

## ១- នីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្ម

### ១.១- ប្រភេទក្រុមហ៊ុនដែលអនុញ្ញាតិដោយក្រសួងពាណិជ្ជកម្ម

សហគ្រាពាណិជ្ជកម្ម ដែលត្រូវបានអនុញ្ញាតិអោយចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម អាចមានប្រភេទដូចតទៅៈ

- សហគ្រាសឯកបុគ្គល
- ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ
- ក្រុមហ៊ុនសហកម្មសិទ្ធិមានកំរិត
- ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត
- សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
- ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត
- គ្រឹះស្ថានសាធារណៈ
- ក្រុមហ៊ុនរដ្ឋ
- ក្រុមហ៊ុនចំរុះ

ប្រភេទក្រុមហ៊ុនទាំងនោះត្រូវមបានទទួលស្គាល់ដោយ ពាណិជ្ជកម្មដូច្នេះដើម្បីអោយក្រុមហ៊ុនទាំងនោះក្លាយយជានីតិបុគ្គលចាំបាច់ត្រូវះ

### ១.២- ការចុះបញ្ជីប្រថាប់ត្រានូវសារលិខិតបង្កើតក្រុមហ៊ុន

លក្ខន្តិកៈ និងកំណត់ហេតុនៃមហាសន្និបាតក្រុមហ៊ុន នៃក្រុមហ៊ុនភាគហ៊ុនដែលបានធ្វើការអំពាវនាវអោយមានការចូលរួមពីសាធារណៈត្រូវតែចុះបញ្ជីប្រថាប់ត្រា។

### ១.៣- ការចុះផ្សាយក្នុងសារពត៌មានស្របច្បាប់

ក្រោយពីការបង្កើតក្រុមហ៊ុនប្រកាសផ្សាយមួយត្រូវ ចុះក្នុងសារពតិមានដែលមានសម្បទាផ្សាយដំណឹងស្របច្បាប់ក្នុងមណ្ឌលរដ្ឋបាលនៃទីស្នាក់ការក្រុមហ៊ុន[23]។

[23] យោងតាមមាត្រា២៥៨ វាក្យខ័ណ្ឌនៃក្រឹត្យច្បាប់លេខ ៦៧-២៣៦។

ក្រុមហ៊ុនត្រូវតែផ្សព្វផ្សាយជាសាធារណៈ ហើយទំរង់នៃការចុះផ្សាយដែលជាទំរង់ការរួមសំរាប់ក្រុមហ៊ុនពាណិជ្ជកម្មទាំងនោះ មានចំនួនពីរបែបៈ[24]

ក- ការចុះផ្សាយសំរង់លិខិតបង្កើតក្រុមហ៊ុន ឬលក្ខន្តិកៈក្នុងសារពត៌មានពិសេស ឬសារពត៌មានសារធារណៈដែលស្របច្បាប់។ និទ្ទេសដែលត្រូវស្រង់ផ្សាយ គឺជានិទ្ទេសដែលស្តីពី ទ្រង់ទ្រាយក្រុមហ៊ុនកម្មវត្ថុចិរវេលា ដើមទុនជាទឹកប្រាក់ ឃីហោឈ្មោះរបស់ក្រុមហ៊ុន ឈ្មោះនិង អាសយដ្ឋាននៃសមាជិកក្រុមហ៊ុន ដែលជាអ្នកទទួលខុសត្រូវផ្ទាល់។

ខ- ប្រសិនបើក្រុមហ៊ុនត្រូវបានបង្កើតតាមលិខិតសាការីប្រកាសផ្សាយនេះត្រូវចុះហត្ថលេខាដោយសាការីនោះ ក្នុងករណីផ្សេងទៀត ត្រូវចុះហត្ថលេខាដោយស្ថាបនិកណាម្នាក់ ឬសមាជិកណាម្នាក់។ គ្មានកំឡុងកាលណាមួយត្រូវបានតំរូវអោយ ធ្វើការចុះផ្សាយការបង្កើតក្នុងសារពត៌មាននោះឡើយ ហើយវាដូចគ្នាដែរ ចំពោះទំរង់ការផ្សាយជាសាធារណៈផ្សេងទៀត (ការតំកល់នៅការិយាល័យក្រឡាបញ្ជីនិងការចុះបញ្ជី)។ មាត្រា២១ នៃគំរោងច្បាប់ខ្មែរ ចែងថាការចុះផ្សាយក៏ដូចជាការតំកល់ទុកត្រូវធ្វើនៅក្នុងខែនៃការតាក់តែងសាលិខិតរបស់ក្រុមហ៊ុន។

## ១.៤- ការតំកល់នៅការិយាល័យក្រឡាបញ្ជី

ត្រូវដាក់តំកល់នៅការិយាល័យក្រឡាបញ្ជីៈ

- សេចក្តីចំលងលក្ខន្តិកៈ ចំនួយ២ច្បាប់ បើសិនជាវាត្រូវបានធ្វើឡើងតាមលិខិតសាការី ឬសំណៅដើមលក្ខន្តិកៈចំនួន ២ច្បាប់ បើសិនជាវាត្រូវធ្វើឡើងជាលិខិតឯកជន។
- សេចក្តីចំលងចំនួន ២ច្បាប់ នូវលិខិតតែងតាំងអង្គការដឹកនាំ ចាត់ការ និងត្រួតពិនិត្យ បើសិនជាពួកគេទាំងឡាយនោះមិនបានតែងតាំងក្នុងលក្ខន្តិកៈ។
- ក្នុងករណីមាន ភាគទុនជាវត្ថុ ក្នុងក្រុមហ៊ុនទទួលខុសត្រូវមានករិត ឬក្រុមហ៊ុនអណាមិករបាយការណ៍របស់ស្នងការភាគទុន ចំនួន២ច្បាប់។
- ក្នុងករណីមាន ការបង្កើតក្រុមហ៊ុនភាគហ៊ុន វិញ្ញាបនប័ត្រនៃអ្នករក្សាទុកចំនួន ២ច្បាប់។
- សេចក្តីប្រកាសអនុលោមភាពចំនួន ២ច្បាប់។

[24] មាត្រា១៩ នៃគំរោងច្បាប់ខ្មែរ។

## ១.៥- ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

ក្រោយពេលបំពេញទំរង់បង្កើតក្រុមហ៊ុន រាប់ការផ្សាយជាសាធារណៈ និងការតំកល់លិខិតបង្កើត និងសេចក្តីប្រកាសអនុលោមភាព នៅការិយាល័យក្រឡាបញ្ជីតុលាការពាណិជ្ជកម្មពាក្យស្នើសុំចុះបញ្ជីត្រូវតែដាក់នៅការិយាល័យ ក្រឡាបញ្ជីតុលាការពាណិជ្ជកម្មនៃអនាគតទីស្នាក់ការក្រុមហ៊ុន។ ទំរង់ការនេះមានសារៈសំខាន់ណាស់ ព្រោះថាគឺចាប់តាំងពីខណៈនៃការចុះបញ្ជីនេះហើយដែលក្រុមហ៊ុនទទួលបាន នីតិបុគ្គលិកលក្ខណៈ។

ក្រឡាបញ្ជីនៅតុលាការពាណិជ្ជកម្ម មានពេល ១៥ថ្ងៃគិតចាប់ពីថ្ងៃទទួលពាក្យសុំ ដើម្បីធ្វើការចុះពញ្ជី ឬធ្វើការជូនដំណឹងទៅអ្នកស្នើសុំនូវសេចក្តីសំរេច ដែលបដិសេធការចុះបញ្ជី។

បើសិនជាគ្មានការចុះពញ្ជីត្រូវបានចាត់ទុកថាត្រូវបានធ្វើ នៅពេលផុតកំឡុងកាលខាងលើនេះហើយក្រឡាបញ្ជីត្រូវធ្វើការចុះពញ្ជីដោយមានបញ្ជាក់កាលបរិច្ឆេទនេះផង។

### ក- លក្ខខណ្ឌនានានៃការចុះបញ្ជី

ប្រភេទក្រុមហ៊ុនដែលបានរៀបរាប់មកហើយ អាចចុះបានត្រូវស្ថិតនៅក្រោមលក្ខខណ្ឌដូចខាងក្រោម៖

- ពាណិជ្ជកម្មជារូបនៃបុគ្គល
- ក្រុមហ៊ុនជាតិ និងគ្រឹះស្ថានសាធារណៈ តាមលក្ខណៈឧស្សាហកម្ម ឬពាណិជ្ជកម្ម និងក្រុមហ៊ុនសេដ្ឋកិច្ចចំរុះ។ ប្រភេទពីរនោះ ត្រូវធ្វើការចុះបញ្ជីក្នុងកាលកំណត់ ១៥ថ្ងៃមុនពេលចាប់ផ្តើមសកម្មភាពរបស់ខ្លួន។
- កម្មសិទ្ធិករនៃមូលនិធិពាណិជ្ជកម្ម ដែលជួលអភិបាល
- ក្រុមហ៊ុនពាណិជ្ជកម្ម
- សម្ព័ន្ធស្វែងរកផងប្រយោជន៍ខាងវិស័យសេដ្ឋកិច្ច
- ក្រុមហ៊ុនបរទេសដែលមានគ្រឹះស្ថាននៅក្នុងប្រទេស
- ក្រុមហ៊ុនស៊ីវិល។

គ្មានកាលកំនត់ណាមួយដែលតំរូវទៅលើនីតិបុគ្គលទាំងនេះ សំរាប់ប្តឹងតវ៉ាពីការចុះបញ្ជីរបស់ខ្លួន ប៉ុន្តែវាទាមទារលក្ខណៈសម្បត្តិអំពើកាចុះបញ្ជី។

ម្យ៉ាងទៀតការចុះបញ្ជីដើមនេះ រូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវទាមទារទទួលយកនៅក្នុងខែនៃការបើកគ្រឹះស្ថានរបស់ខ្លួន បើសិនជាវា ធ្វើអាជីវកម្មនៅគ្រឹះស្ថានបន្ទាប់បន្សំ គឺការចុះឈ្មោះបំពេញបន្ថែមត្រូវធ្វើអាជីវកម្មកាលណាគ្រឹះស្ថាននេះត្រូវស្ថិតក្នុងដែនអំណាចតុលាការនៅទីកន្លែងដែលត្រូវសុំចុះឈ្មោះដើម។ ហើយការចុះបញ្ជីបន្ទាប់បន្សំមួយត្រូវបានធ្វើ បើសិនជាគ្រឹះស្ថានត្រូវស្ថិតនៅក្នុងដែនអំណាចផ្សេងនោះ ការចុះបញ្ជីបន្ទាប់បន្សំនេះបញ្ជូនទៅធ្វើការចុះបញ្ជីដើមនៅក្រឡាបញ្ជីតុលាការក្នុងដែនអំណាចនៃតុលាការដែលវាស្ថិតនៅ។

## ខ- នីតិវិធីនៃការចុះបញ្ជី

គ្រប់ក្រុមហ៊ុនដែលមានសកម្មភាព ពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជាត្រូវចុះបញ្ជីពាណិជ្ជកម្មទោះបីបែបបទនៃការបង្កើតនិង ចិរវេលា របស់ក្រុមហ៊ុនទាំងនោះមានលក្ខណៈបែបណាក៏ដោយ។

ការចុះឈ្មោះនេះត្រូវធ្វើឡើងដោយអភិបាលនៃសាមីក្រុមហ៊ុននោះ នៅក្នុងខែនៃការបង្កើតក្រុមហ៊ុននិង១៥ថ្ងៃ មុនកាលបរិច្ឆេទ បើកប្រតិបត្តិការពាណិជ្ជកម្ម។ ចំពោះការចុះបញ្ជីនេះ មានលក្ខណៈខុសគ្នាបន្តិចបន្តួចទៅតាមទំរង់នៃក្រុមហ៊ុន ឬ សហគ្រាស។

### ខ.១- សហគ្រាសឯកបុគ្គល

សហគ្រាសឯកបុគ្គល ដែលបានបង្កើតឡើង និង ជាប់ពន្ធលើប្រាក់ចំណេញត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។ ឯកកម្មសិទ្ធិករដែលជាម្ចាស់ដើមទុននៃសហគ្រាស ឬអាណត្តិគាហកត្រូវមកបំពេញបែបបទសុំចុះបញ្ជីពាណិជ្ជកម្មនៅតាមមន្ទីរពាណិជ្ជកម្មខេត្តដែលខ្លួនធ្វើអាជីវកម្ម ឬ នៅនាយកដ្ឋាននីតិកម្មនៃក្រសួង ពាណិជ្ជកម្ម។

សំណុំលិខិតដែលត្រូវផ្តល់ជូនមន្ត្រីចុះបញ្ជីពាណិជ្ជកម្មមាន:

១.ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម ចំនួន ០២ ច្បាប់

២.ថតចម្លងលិខិតអនុញ្ញាតិធ្វើអាជីវកម្ម(ប្រសិនបើមាន) ចំនួន ០២ ច្បាប់

៣.ថតចម្លងអត្តសញ្ញានប័ណ្ណ ឬ លិខិតឆ្លងដែន ចំនួន ០២ ច្បាប់

៤.រូបថត ៤X៦ ចំនួន ០២ ច្បាប់

៥.ថតចម្លងកម្មសិទ្ធិផ្ទះជាទីតាំងសហគ្រាស ឬកិច្ចសន្យាជួលផ្ទះ ចំនួន ០២ ច្បាប់

⌖ សំណុំលិខិតដែលត្រូវផ្តល់មាន:

១.ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម ចំនួន ០២ ច្បាប់

២.លក្ខន្តិកៈនិងបទពញ្ញាផ្ទៃក្នុងក្រុមហ៊ុន(ច្បាប់ដើម) ចំនួន ០២ ច្បាប់

៣.ប្រតិវេទណ៍នៃអនុលោមភាព ចំនួន ០២ ច្បាប់

៤.ពាក្យសុំចុះផ្សាយក្នុងសារពត៌មាន ចំនួន ០២ ច្បាប់

៥.ថតចម្លងអត្តសញ្ញាណប័ណ្ណ របស់អភិបាលនិងសមាជិកក្រុមហ៊ុនម្នាក់ចំនួន ០២ ច្បាប់

៦.រូបថតទំហំ ៤X៦ របស់អភិបាលនិងសមាជិកក្រុមហ៊ុន ម្នាក់ចំនួន ០២ ច្បាប់

៧.សេចក្តីប្រកាសពញ្ញាក់ការគ្មានជាប់ទោសពិរុទ្ធណាមួយរបស់អភិបាល ចំនួន ០២ ច្បាប់

៨.សេចក្តីសំរេចដាក់ភាគទុន(បើជានីតិបុគ្គលចូលរួម)

៩.ករណីទីស្នាក់ការតាំងនៅផ្ទះរបស់សមាជិកណាម្នាក់ក្នុងក្រុមហ៊ុនត្រូវផ្តល់:

➢ថតចម្លងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ(កម្មសិទ្ធិផ្ទះ) ចំនួន ០២ ច្បាប់

-ករណីទីស្នាក់ការតាំងនៅផ្ទះជួលគេត្រូវផ្តល់:

➢កិច្ចសន្យាជួលផ្ទះ ចំនួន ០២ ច្បាប់

-ករណីទីស្នាក់ការតាំងនៅសណ្ឋាគាររយៈពេលតិចជាង ១ឆ្នាំត្រូវផ្តល់

➢លិខិតបញ្ជាក់ការជួលការិយាល័យរបស់សណ្ឋាគារ(ចេញដោយម្ចាស់សណ្ឋាគារ) ចំនួន ០២ ច្បាប់

## ខ.២- ទំរង់ការសំរាប់ចុះបញ្ជីសហគ្រាសសាធារណៈ

អភិបាល ឬសមាជិកក្រុមហ៊ុនម្នាក់ ត្រូវមកបំពេញដោយផ្ទាល់នូវបែបបទសុំចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្មនៅនាយកដ្ឋននីតិកម្មនៃក្រសួងពាណិជ្ជកម្ម។

អភិបាល ឬសមានជិកក្រុមហ៊ុន ដែលទទួលភារកិច្ចនេះ ត្រូវបង្ហាញជូនមន្ត្រីចុះបញ្ជីនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ខ្លួន។ អភិបាល ឬ សមាជិកក្រុមហ៊ុននេះត្រូវចុះហត្ថលេខាដោយផ្ទាល់ដៃនៅចំពោះមុខមន្ត្រីនាយកដ្ឋននីតិកម្ម ធានាអះអាង និងទទួលខុសត្រូវលើរាល់សំណុំលិខិត ដែលខ្លួនបានយកមកតំកល់ទុកនៅនាយកដ្ឋាននីតិកម្ម ថាពិតជាគ្រប់គ្រាន់ និង ត្រឹមត្រូវមិនមានក្លែងបន្លំលើប្រការណាមួយឡើង។

បើក្នុងករណីដែលពីនិត្យឃើញថា មានភាពមិនច្បាស់លាស់ក្នុងលិខិត ឬឯកសារណាមួយ ប្រធាននាយកដ្ឋាននីតិកម្ម ត្រូវកោះអញ្ជើញប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ឬអភិបាលណាម្នាក់មកបំភ្លឺ និងដោះស្រាយទៅតាមករណីនីមួយៗ។

⌘ សំណុំលិខិតដែលត្រូវផ្តល់មានៈ

| | |
|---|---|
| ១.ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម | ចំនួន ០២ ច្បាប់ |
| ២.លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន(ច្បាប់ដើម) | ចំនួន ០២ ច្បាប់ |
| ៣.ប្រតិវេទណ៍នៃអនុលោមភាព | ចំនួន ០២ ច្បាប់ |
| ៤.ពាក្យសុំចុះផ្សាយក្នុងសារពត៌មាន | ចំនួន ០២ ច្បាប់ |
| ៥.ថតចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អភិបាល និង សមាជិកក្រុមហ៊ុន | ម្នាក់ចំនួន ០២ ច្បាប់ |
| ៦.រូបថតទំហំ ៤X៦ របស់អភិបាលនិងសមាជិកក្រុមហ៊ុន | ម្នាក់ចំនួន ០២ ច្បាប់ |
| ៧.សេចក្តីប្រកាសពញ្ជាក់ការគ្មានជាប់ទោសពិរុទ្ធណាមួយ | |

របស់អភិបាល ចំនួន ០២ ច្បាប់

៨.ករណីទីស្នាក់ការតាំងនៅផ្ទះរបស់សមាជិកណាម្នាក់ក្នុងក្រុមហ៊ុនត្រូវផ្តល់:

➢ថតចម្លងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ(កម្មសិទ្ធិផ្ទះ) ចំនួន ០២ ច្បាប់

-ករណីទីស្នាក់ការតាំងនៅផ្ទះជួលគេត្រូវផ្តល់:

➢កិច្ចសន្យាជួលផ្ទះ ចំនួន ០២ ច្បាប់

-ករណីទីស្នាក់ការតាំងនៅសណ្ឋាគាររយៈពេលតិចជាង ១ឆ្នាំត្រូវផ្តល់

➢លិខិតបញ្ជាក់ការជួលការិយាល័យរបស់សណ្ឋាគារ(ចេញដោយម្ចាស់សណ្ឋាគារ) ចំនួន ០២ ច្បាប់

៩.អនុក្រឹត្យបង្កើតសហគ្រាស

១០.អនុក្រឹត្យតែងតាំងប្រធានអគ្គនាយក-អគ្គនាយក-សមាជិកក្រុមប្រឹក្សាភិបាល

### ខ.៣- ទំរង់ការសំរាប់ចុះបញ្ជីតំណាង ឬទីភ្នាក់ងារ និងសាខាក្រុមហ៊ុនបរទេស

អភិបាលការិយាល័យតំណាង-ទីភ្នាក់ងារ-សាខាក្រុមហ៊ុន ឬអណត្តិគាហក ត្រូវមកបំពេញដោយផ្ទាល់នូវបែបបទសុំចុះឈ្មោះការិយាល័យតំណាង-ទីភ្នាក់ងារ-សាខាក្រុមហ៊ុន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជាក្នុងបញ្ជីពាណិជ្ជកម្ម នៅនាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម។

អភិបាល ឬអាណត្តិគាហក ដែលទទួលភារកិច្ចនេះ ត្រូវបង្ហាញជូនមន្ត្រីចុះបញ្ជីនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ខ្លួន។ អភិបាល ឬអាណត្តិគាហក ត្រូវចុះហត្ថលេខាដោយផ្ទាល់ដៃនៅចំពោះមុខមន្ត្រីនាយកដ្ឋាននិតិកម្មធានាអះអាង និងទទួលខុសត្រូវលើរាល់លិខិតដែលខ្លួនបានយកមកតំកល់ទុកនៅនាយកដ្ឋាននីតិកម្មថាពិតជាគ្រប់គ្រាន់និងត្រឹមត្រូវ មិនមានក្លែងបន្លំលើប្រការណាមួយឡើយ។

បើក្នុងករណីដែលពិនិត្យឃើញថា មានភាពមិនច្បាស់លាស់ក្នុងលិខិត ឬឯកសារណាមួយ ប្រធាននាយកដ្ឋាននីតិកម្មត្រូវកោះអញ្ជើញអភិបាលការិយាល័យតំណាងទីភ្នាក់ងារ សាខាក្រុមហ៊ុននោះ ឬអាណត្តិគាហក មកបំភ្លឺ និងដោះស្រាយទៅតាមករណីនីមួយៗ។

✠សំណុំលិខិតដែលត្រូវផ្តល់មាន៖

១.ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម ចំនួន ០២ ច្បាប់

២.ថតចម្លងលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនដើម

"មានបញ្ជាក់ថាពិតជាត្រឹមត្រូវតាមច្បាប់" ចំនួន ០២ ច្បាប់

៣.ថតចម្លងវិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើម

"មានបញ្ជាក់ថាពិតជាត្រឹមត្រូវតាមច្បាប់" ចំនួន ០២ ច្បាប់

៤.លិខិតតែងតាំងអភិបាលការិយាល័យតំណាង-ទីភ្នាក់ងារ-សាខា ចំនួន ០២ ច្បាប់

៥.ថតចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អភិបាល

ការិយាល័យតំណាង-ទីភ្នាក់ងារ-សាខា ម្នាក់ចំនួន ០២ ច្បាប់

៦.រូបថតទំហំ ៤X៦ របស់អភិបាលនិងសមាជិកក្រុមហ៊ុន ម្នាក់ចំនួន ០២ ច្បាប់

៧.សេចក្តីប្រកាសពញ្ជាក់ការគ្មានជាប់ទោសពិរុទ្ធណាមួយ

របស់អភិបាល ចំនួន ០២ ច្បាប់

៨.សេចក្តីសំរេចដាក់ភាគទុន(បើជានីតិបុគ្គលចូលរួម)

៩.ករណីទីស្នាក់ការតាំងនៅផ្ទះរបស់សមាជិកណាម្នាក់ក្នុងក្រុមហ៊ុនត្រូវផ្តល់:

➢ថតចម្លងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ(កម្មសិទ្ធិផ្ទះ) ចំនួន ០២ ច្បាប់

-ករណីទីស្នាក់ការតាំងនៅផ្ទះជួលគេត្រូវផ្តល់:

➢កិច្ចសន្យាជួលផ្ទះ ចំនួន ០២ ច្បាប់

-ករណីទីស្នាក់ការតាំងនៅសណ្ឋាគាររយៈពេលតិចជាង ១ឆ្នាំត្រូវផ្តល់

➢លិខិតបញ្ជាក់ការជួលការិយាល័យរបស់សណ្ឋាគារ(ចេញដោយម្ចាស់សណ្ឋាគារ) ចំនួន ០២ ច្បាប់។

## ខ.៤- ពាក្យសុំចុះបញ្ជីពាណិជ្ជកម្មត្រូវបង្កើតជា ៣ច្បាប់

- វាមានពត៌មានដែលប្រែប្រួលទៅតាមពាណិជ្ជករ ដែលជារូបវន្តបុគ្គល ឬនីតិបុគ្គល។
- សំរាប់រូបវន្តបុគ្គល វាគួសបញ្ជាក់ជាអាទ៏នូវឈ្មោះ(នាម) គោត្តនាម លំនៅដ្ឋាន កាលបរិច្ឆេទ ទីកន្លែងកំណើត សញ្ជាតិ កាលបរិច្ឆេ ទីកន្លែងរៀបអាពាហ៍ពិពាហ៍ និងរបបអាពាហ៍ពិពាហ៍ដែលវាទទួលយក។
- សំរាប់នីតិបុគ្គល វាកំណត់ពីយីហោក្រុមហ៊ុន ឬឈ្មោះក្រុមហ៊ុន មូលធនក្រុមហ៊ុនទំរង់ និង ចិរវេលាក្រុមហ៊ុន នាម គោត្តនាម និងលំនៅដ្ឋាន បណ្ណាធិការ អភិបាលក្រុមហ៊ុន នាមរបស់សមាជិកក្រុមហ៊ុន ទាមទារអោយទទួលខុសត្រូវគ្មានកំនត់និងសាមគ្គីចំពោះប្រាក់បំណុលក្រុមហ៊ុន។
- គ្រប់ករណីទាំងអស់ ពាក្យសុំត្រូវមានការរៀបរាប់ពីសកម្មភាពដែលត្រូវអនុវត្តនៅអាស័យដ្ឋាននៃគ្រឹះស្ថានដើម និង គ្រឹះស្ថានបន្ទាប់បន្សំ និងការធ្វើអោយសមហេតុផលនៅលទ្ធកម្មមូលនិធិ។

## ខ.៥- ការផ្ញើទុកពាក្យសុំ

ពាក្យសុំដែលមានចុះហត្ថលេខា ដោយពាណិជ្ជករ ឬអ្នកតំណាងក្រុមហ៊ុន ត្រូវបានតំកល់ទុកនៅមន្ទីរក្រឡាបញ្ជីតុលាការពាណិជ្ជកម្ម។

លេខាក្រឡាបញ្ជីក្រោមការទទួលខុសត្រូវរបស់ខ្លួន ធានាគ្រប់ការចុះនិទ្ទេសទាំងអស់ត្រូវកំណត់ដោយអត្តបទច្បាប់ មានចែងក្នុងសេចក្តីប្រកាស ធានាថាគ្រប់សំណុំឯកសារសមហេតុផលត្រូវបានបង្កើត លេខាក្រឡាបញ្ជីផ្តល់ជូន លេខរៀងមួយដើម្បីគ្រប់គ្រង។

គ្រប់ការតវ៉ាទាំងអស់ ដីកាជាលើកដំបូង ការប្តឹងអោយសើរើជាថ្មីឡើងវិញ ត្រូវធ្វើក្នុងរយៈពេល ១៥ថ្ងៃនៅចំពោះមុខតុលាការពាណិជ្ជកម្ម។

### ខ.៦- ការបញ្ជូនពាក្យសុំ

ពាក្យសុំអត្តសញ្ញាណកម្មត្រូវបញ្ជូនទៅវិទ្យាស្ថានជាតិខាងស្ថិតិ និងខាងសិក្សាសេដ្ឋកិច្ចដែលត្រូវធ្វើដោយលេខាក្រឡាបញ្ជី។

វិទ្យាស្ថាននេះផ្តល់ជូនអ្នកសុំ នូវលេខរៀងពីអត្តសញ្ញាណកម្ម និងពត៌មានមកលេខាក្រឡាបញ្ជីដែលចុះនិទ្ទេសលើសំណុំរឿង និងជូនដំណឹងដល់អ្នកដែលជាប់ពាក់ព័ន្ធ ដោយផ្ទាល់អោយវាមួយនៃបណ្តាច្បាប់ ដើមនៃពាក្យសុំរបស់វា ដែលបំពេញតាមលេខរៀងនៃការចុះបញ្ជី។

វិទ្យាស្ថានជាតិខាងស្ថិតិ និងការសិក្សាសេដ្ឋកិច្ចមានកំរងអត្តបទជាតិ ខាងសហគ្រាស និងគ្រឹះស្ថានវាបានបង្កើតនូវប្រព័ន្ធពត៌មានសំរាប់កំរងអត្តបទសហគ្រាស និងគ្រឹះស្ថាន។

- វិទ្យាស្ថាននេះផ្តល់អោយសហគ្រាសនីមួយៗនូវ:
  - លេខរៀងតាមលំដាប់បង្កើតជា ៩សន្ទស្សន៍
  - លេខរៀងសំរាប់គ្រឹះស្ថាននីមួយៗ

**ឧទាហរណ៍**

- លេខរៀងនៃការចុះបញ្ជីត្រូវមាន
- ចង្អុលបង្ហាញពី RCS
- នាមទីស្នាក់ការរបស់តុលាការពាណិជ្ជកម្ម
- ពីA.B.C.Dទៅតាមប្រភេទ:
  - A- រូបវន្តបុគ្គល
  - B- ក្រុមហ៊ុនពាណិជ្ជកម្ម(នីតិបុគ្គល)
  - C- សម្ព័ន្ធស្វែងរកផលប្រយោជន៍ខាងវិស័យសេដ្ឋកិច្ច
  - D- ក្រុមហ៊ុនស៊ីវិល
- R.C.S. PARIS B-380-740-989

លេខរៀងនេះ អ្នកជាប់ពាក់ព័ន្ធ ត្រូវទាមទារអោយដាក់លេខរៀងនេះ នៅក្បាលគ្រប់លិខិតពាណិជ្ជកម្មទាំងអស់៖

- វិក័យប័ត្រ
- តារាងតំលៃទំនិញ
- លិខិតឆ្លើយឆ្លង
- ឯកសារផ្សព្វផ្សាយផ្សេងៗ

នៅក្នុងពេល ៨ថ្ងៃ នៃការចុះបញ្ជីទៅក្នុងបណ្តឹងសុំ នៅលេខាក្រឡាបញ្ជីនិងក្រោមការទទួលខុសត្រូវរបស់ខ្លួនត្រូវធ្វើការផ្សព្វផ្សាយនៅ BODAC។

## ១.៦- កម្រៃរដ្ឋបាលក្នុងការចុះឈ្មោះក្រុមហ៊ុន លុបឈ្មោះ និងចេញវិញ្ញាបនបត្រ

កម្រៃរដ្ឋបាលក្នុងការចុះឈ្មោះក្រុមហ៊ុន លុបឈ្មោះ និងចេញវិញ្ញាបនបត្រផ្សេងៗ ក្នុងបញ្ជីពាណិជ្ជកម្ម ត្រូវបានកំណត់ដូចខាងក្រោម[25] :

| បរិយាយ | កម្រៃសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | កម្រៃសុំលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម | កម្រៃសុំវិញ្ញាបនបត្រផ្សេងៗ |
|---|---|---|---|
| **១- ក្រុមហ៊ុនពាណិជ្ជកម្ម** | ៤២០.០០០រៀល | ២០០.០០០រៀល | ៦០.០០០រៀល |
| ក្នុងនោះ : | | | |
| -ការសុំចុះឈ្មោះ | ២៦០.០០០រៀល | | |
| -ទម្រង់បែបបទសុំចុះបញ្ជី | ១២០.០០០រៀល | | |
| -ផែកឈ្មោះ | ២០.០០០រៀល | | |
| -ផ្តល់អត្តលេខ | ២០.០០០រៀល | | |
| **២- សហគ្រាសឯកបុគ្គល** | ១២០០.០០រៀល | ៦០.០០០រៀល | ២០.០០០រៀល |

[25] ប្រការ២ នៃប្រកាសជាអន្តរក្រសួងស្តីពីកម្រៃរដ្ឋបាលក្នុងការចុះបញ្ជីពាណិជ្ជកម្មឆ្នាំ២០០៧។

### ១.៧- បែបបទ និង នីតិវិធីកែប្រែលក្ខន្តិកៈ

ក្រោយការចុះបញ្ជីពាណិជ្ជកម្ម ក្នុងដំណើរការអាជីវកម្មរបស់ខ្លួន ក្រុមហ៊ុនអាចធ្វើការកែប្រែលក្ខន្តិកៈបានគ្រប់ពេលវេលា។ ការកែប្រែលក្ខន្តិកៈ អាចធ្វើទៅបានដូចខាងក្រោម[26] :

- ការផ្លាស់ប្តូរនាមករណ៍ក្រុមហ៊ុន។
- ការបន្ថែមការបន្ថយ ឬការផ្លាស់ប្តូរគោលបំណងកម្មវត្ថុ អាជីវកម្ម ឬសកម្មភាពប្រកបពាណិជ្ជកម្មរបស់ក្រុមហ៊ុន។
- ការបែងចែកសារជាថ្មីនូវចំនួនភាគហ៊ុនជាប្រភេទឡើងវិញ ដែលមានការកែប្រែលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់ប្រភេទភាគហ៊ុនណាមួយ។
- ការកែប្រែភាគលាភ នៃប្រភេទភាគហ៊ុនណាមួយ។
- ការបន្ថយដើមទុនដោយបង្កើតភាគហ៊ុនប្រភេទថ្មីដែលមានលក្ខណៈដាច់ខាត និងលក្ខណៈធៀបប្រសើរ ឬទាបជាងប្រភេទភាគហ៊ុនដែលមានរួចហើយ។
- ការកែប្រែចិរវេលានៃអត្ថិភាពរបស់ក្រុមហ៊ុន។
- ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជី។
- ការកែប្រែចំនួនកូរ៉ុម......។

## ២- ការចុះបញ្ជីអាជ្ញាបណ្ណ័នៅក្នុងក្រសួងស្ថាប័នពាក់ព័ន្ធ

### ២.១- ពន្ធ និង ពន្ធប្រថាប់ត្រា

ក្រុមហ៊ុន ឬសាខាក្រុមហ៊ុន ឬការិយាល័យតំណាងទើបនិងបង្កើតថ្មីទាំងអស់តម្រូវឱ្យចុះ បញ្ជីជាមួយការិយាល័យសាខាពន្ធដារមូលដ្ឋាន នៃនាយកដ្ឋានពន្ធដារហើយត្រូវបង់ពន្ធប្រថាប់ ត្រាក្រុមហ៊ុន ក្នុងរយះពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម។ ក្នុងរយះពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មរាល់អាជីវកម្ម ដែលបានចុះបញ្ជីទាំងអស់ត្រូវទៅកាន់ការិយាល័យសាខាពន្ធដារខេត្តក្រុង របស់ខ្លួននៅក្នុងមូល ដ្ឋានដែលអាជីវកម្មបិតនៅ ដើម្បីបង់ពន្ធរដ្ឋាភិបាលមូលដ្ឋា/ពន្ធប្រថាប់ត្រា។ ចំនួនទឹកប្រាក់ដែល ត្រូវបង់អាចប្រហែលទៅតាមពេលវេលា ប៉ុន្តែក្នុងខណៈពេលនៃការតាក់តែងសៀវភៅនេះចំនួន នេះគឺ ១៩៩,០០

[26] ប្រការ២ នៃប្រកាសស្តីពីបែបបទ និងនីតិវិធី កែប្រែលក្ខន្តិកៈក្រុមហ៊ុនឆ្នាំ២០០៦ របស់ក្រសួងពាណិជ្ជកម្ម។

រៀល សំរាប់ក្រុមហ៊ុន និង ១១៥,០០០ រៀល សម្រាប់សាខាក្រុមហ៊ុនពាណិជ្ជ កម្ម ឬការិយាល័យតំណាង។ ឧទាហរណ៍ ក្រុមហ៊ុនមួយ មានទីតាំងអាជីវកម្មរបស់ខ្លួនស្ថិតនៅ រាជធានីភ្នំពេញ ដូចនេះត្រូវទៅសាខាពន្ធដារាជធានីភ្នំពេញ ។

**ឯកសារដែលត្រូវភ្ជាប់ជាមួយ មានដូចខាងក្រោម:**

- លខន្តិក:ក្រុមហ៊ុន (១ ច្បាប់ដើម និង ២ ច្បាប់ថតចំលង)
- វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម
(១ ច្បាប់ដើម និង ២ ច្បាប់ ថតចំលង)
- អាជ្ញាប័ណ្ណអាជីវកម្មពីក្រសួងពាណិជ្ជកម្ម (១ច្បាប់ដើម និង ២ច្បាប់ថតចំលង)
- កិច្ចព្រមព្រៀងជួលទីតាំងអាជីវកម្ម (១ច្បាប់ដើម និង ១ច្បាប់ថតចំលង)
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (១ ច្បាប់ថតចំលង)

ប្រសិនបើ អ្នកជួលឱ្យជារូបវន្តបុគ្គលកិច្ចព្រមព្រៀងជួលទីតាំងអាជីវកម្មណាមួយត្រូវតែបង្ហាញជាមួយបង្កាន់ដៃពន្ធប៉ាតង់នៃការជួល ( ម្ចាស់ផ្ទះ / អ្នកជួលឱ្យ ) ឬប្រសិនបើអ្នកជួលឱ្យគឺ ជាក្រុមហ៊ុន ឬអាជីវកម្មដែលបង់ពន្ធតាមរបបពិតត្រូវបង្ហាញប័ណ្ណប៉ាតង់និងវិញ្ញាបនប័ត្រចុះបញ្ជី អាករលើតម្លៃបន្ថែម "អតប" ។ បើទីតាំងអាជីវកម្មនោះ ជាកម្មសិទ្ធរបស់ម្ចាស់អាជីវកម្ម ត្រូវបង្ហាញសៀវភៅគ្រួសារ និង លិខិតរបស់អាជ្ញាធរមូលដ្ឋានដែលបញ្ជាក់ពីកម្មសិទ្ធលើទីតាំងនោះ។ ប័ណ្ណកម្មសិទ្ធដីធ្លីក៏ត្រូវបាន តំរូវឱ្យមាន ផងដែរប្រសិនបើដីនោះគឺជាកម្មសិទ្ធរបស់ម្ចាស់អាជីវកម្ម។ ចំពោះអាជីវកម្មដ៏ទៃ ទៀតដែលបានចុះបញ្ជី រួចហើយបានបង់ពន្ធប្រថាប់ត្រារួចហើយ និង បានអនុញ្ញាតអោយអាជីវ កម្មដែលចុះបញ្ជីប្រើប្រាស់ទីតាំងរបស់ខ្លួនត្រូវបង្ហាញលិខិត / កិច្ចព្រមព្រៀងប្រើប្រាស់ទីតាំង បង្កាន់បង់ពន្ធប៉ាតង់លើការជួលទីតាំង នៃអាជីវកម្មដែលត្រូវបានអនុញ្ញត ( ក្នុងករណីជួលទីតាំង) ឬ ភស្តុតាងនៃប័ណ្ណកម្មសិទ្ធអចលនវត្ថុដែលអនុញ្ញាតឱ្យក្រុមហ៊ុនកាន់កាប់ទីតាំង។

ដល់ចំនុចនេះអាជីវកម្មមានលក្ខន្តិក:ក្រុមហ៊ុន វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម និង អាជ្ញាប័ណ្ណអាជីវកម្មដែលត្រូវបានបោះត្រានិងចុះកាលបរិច្ឆេទ។

## ២.២- ការបង់ពន្ធ

ជំហានបន្ទាប់សម្រាប់អាជីវកម្មដែលបាន ចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម គឺត្រូវទៅការិយាល័យគ្រប់គ្រងអ្នលជាប់ពន្ធធំ និងមធ្យមនៃនាយកដ្ឋានពន្ធដារ ដើម្បីបង់ពន្ធដារ និងទទួល

អត្ត សញ្ញាណកម្មសារពើពន្ធប្រសិនបើទីតាំងចុះបញ្ជីអាជីវកម្មស្ថិតនូវរាជធានីភ្នំពេញ ឬ ប្រសិនបើទីតាំងចុះបញ្ជីនៅខេត្ត ក្រុង ត្រូវទៅកាន់ការិយាល័យសាខាពន្ធដារខេត្ត ក្រុង។

ឯកសារដែលត្រូវភ្ជាប់មកជាមួយ មានដូចខាងក្រោម:

- វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម ចេញដោយក្រសួងពាណិជ្ជកម្ម ( ១ ច្បាប់ដើម និង ២ ច្បាប់ថតចំលង)
- អាជ្ញាប័ណ្ណអាជីវកម្ម ចេញដោយក្រសួងពាណិជ្ជកម្ម (១ច្បាប់ដើម និងថតចំលង ២ ច្បាប់ )
- រូបថតរបស់តំណាងស្របច្បាប់ចំនួន ២ សន្លឹក ( 4x6cm )
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកដាក់ពាក្យ ( ១ ច្បាប់ )
- ពាក្យសុំបង់ពន្ធប៉ាតង់បាន បំពេញសព្វគ្រប់ និង មានចុះហត្ថលេខា ( ២ ច្បាប់ដើម )
- បង្កាន់ដៃផ្លូវការពីមន្ទីពន្ធដារខេត្ត(១ច្បាប់ថតចម្លង)
- កិច្ចព្រមព្រៀងជួលថតចំលង ប្រសិនបើពាក់ព័ន្ធ(១ច្បាប់ថតចំលង)
- លិខិតអនុញ្ញាតអោយដាក់ទីតាំងអាជីវកម្មសាលាខេត្ត ក្រុង ប្រសិនបើមាន
- លក្ខន្តិកៈក្រុមហ៊ុន ( ១ ច្បាប់ដើម និង ២ ច្បាប់ថតចំលង )
- លិខិតអនុញ្ញាតអាជីវកម្មដទៃទៀតដែលទទួលបាន

ដូចបញ្ជាក់ខាងលើ អាជីវកម្មត្រូវតែបង់ពន្ធប៉ាតង់សម្រាប់ឆ្នាំដំបូង។ ពន្ធ នេះគឺជាពន្ធចុះ បញ្ជីអាជីវកម្មប្រចាំឆ្នាំ។ ប្រសិនបើការចុះបញ្ជីនៅពាក់កណ្តាលឆ្នាំនៃឆ្នាំប្រតិទិន ( និងឆ្នាំសារពើ ពន្ធរបស់រាជរដ្ឋាភិបាល) (ថ្ងៃទី ១ កក្កដា ដល់ ថ្ងៃទី ៣១ ខែ ធ្នូ) នោះការបង់ពន្ធត្រូវគិតពាក់ កណ្តាលឆ្នាំ។ ពន្ធប្រចាំឆ្នាំមានចំនួន ១,១៤០,០០០ (មួយលានមួយសែនបួនម៉ឺន) រៀល (ប្រហែល ៣០០ ដុល្លារ)។ ការបង់បន្ធប៉ាតង់លើកដំបូង ត្រូចតែធ្វើឡើងក្នុងរយៈពេល១៥ថ្ងៃគិត ចាប់ពីថ្ងៃចុះបញ្ជីពាណិជ្ជកម្ម។ ពន្ធប៉ាតង់ ត្រូវបង់ជារៀងរាល់ឆ្នាំសម្រាប់អាជីវកម្មនីមួយៗ របស់ ក្រុមហ៊ុន និងទីតាំងអាជីវកម្មនីមួយៗ គឺថាអាជីវកម្ម ត្រូវជូនដំណឹងទៅអាជ្ញាធរពន្ធដារ ថាគេមាន សកម្មភាពអាជីវកម្មពីរ ឬច្រើន ដូចនេះពន្ធប៉ាតង់ត្រូវតែមានសម្រាប់អាជីវកម្ម។

អាជីវកម្មនិងទទួលបានពាក្យសុំបង់ពន្ធប៉ាតង់ និងបង្កាន់ដៃផ្លូវការ ប័ណ្ណប៉ាតង់លិខិតផ្លូវ ការពីការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យម ដើម្បីបញ្ជាក់ពីការចុះបញ្ជីពន្ធដារ ដែលនេះ រួមមានទាំង លេខអត្តសញ្ញាណកម្មពន្ធដារផងដែរ។

### ២.៣- ពន្ធប៉ាតង់

គ្រប់សហគ្រាសពាណិជ្ជកម្មទាំងអស់ ត្រូវតែចុះបញ្ជីប្រចាំឆ្នាំនៅនាយកដ្ឋានពន្ធដារ និង ត្រូវបង់ពន្ធប៉ាតង់ (ស្រដៀងនិងពន្ធចុះបញ្ជីអាជីវកម្ម) ចំនួន ១,១៧០,០០០ រៀល (ប្រហែលនិង ២៨៥ ដុល្លា) នៅមុនថ្ងៃទី ៣១ ខែមិនា រៀងរាល់ឆ្នាំ។ ប័ណ្ណប៉ាតង់ និងត្រូវបានចេញអោយដោយ នាយកដ្ឋានពន្ធដារ ក្រោយពេលដែលបានបង់ពន្ធរួច។

ប្រសិនបើអ្នកជាប់ពន្ធមានសកម្មភាពមានសកម្មភាពអាជីវកម្មផ្សេងៗ ទៀតនោះតម្រូវ អោយមានប័ណ្ណប៉ាតង់ដាច់ដោយឡែកសម្រាប់សកម្មភាពអាជីវកម្មដែលខុសៗគ្នាទាំងនោះ ។ ជាងនេះទៅទៀត ប្រសិនបើអ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មនៅក្នុងក្រុង ឬ ខេត្តផ្សេង ៗ គ្នានោះក្រុមហ៊ុនតម្រូវអោយ មានប័ណ្ណប៉ាតង់សម្រាប់ទីតាំងនីមួយៗនោះផងដែរ។

## ៣- ការរំលាយ និង ការជម្រះបញ្ជីក្រុមហ៊ុន

កាលណាបើពាណិជ្ជករណាម្នាក់ឈប់ប្រកបពាណិជ្ជកម្មរបស់ខ្លួន ឬទទួលមរណៈភាពដោយពុំបានធ្វើអនុប្បទាននូវមូលនិធិពាណិជ្ជកម្មរបស់ខ្លួន ឬកាលណាបើក្រុមហ៊ុនណាមួយត្រូវរលាយនោះ ត្រូវលុបឈ្មោះពាណិជ្ជករនោះ ឬក្រុមហ៊ុននោះចេញពីបញ្ជី។

បើសិនជា គ្មានការសុំលុបឈ្មោះដោយពាណិជ្ជករ ឬដោយអ្នកទទួលមរតក ឬដោយអ្នកជំរះបញ្ជី ការលុបឈ្មោះចេញពីបញ្ជីនេះ ត្រូវធ្វើឡើងដោយបញ្ញត្តិ តាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ រាល់ឯកសារដែលពាក់ព័ន្ធនឹងការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ត្រូវចម្លងជូនទៅតុលាការពាណិជ្ជកម្មដើម្បីតម្កល់ជាឯកសារសំរាប់យុត្តាធិការពាណិជ្ជកម្ម[27]។

គ្រប់រូបវន្តបុគ្គលនៅក្នុងខែ នៃការបញ្ឈប់សកម្មភាពរបស់ខ្លួនត្រូវស្នើសុំលុបចោលសកម្មភាពរបស់ខ្លួនពីសៀវភៅបញ្ជីពាណិជ្ជកម្ម តាមកំណត់កាលបរិច្ឆេទនៃការបញ្ឈប់របស់ខ្លួន។ សំរាប់នីតិបុគ្គល ការលុបចោលត្រូវស្នើសុំក្នុងខែដែលបន្ទាប់ពីការបិទនូវ ប្រតិបត្តិការនៃការជំរះបញ្ជី។

ដោយសារតែ ក្រុមហ៊ុនត្រូវបានបង្កើតឡើងក្រោមរូបភាពជាកិច្ចសន្យាក្រុមហ៊ុន ដែលមានលក្ខណៈស្របទៅតាមច្បាប់កំណត់ ហើយការរំលាយទៅវិញនៃក្រុមហ៊ុននេះ វានឹងផ្តល់នូវផលអវិជ្ជមានជាច្រើនទៅដល់ សង្គម ក៏ដូចប្រទេសជាតិទាំងមូល ពោលវាមិនមែនគ្រាន់តែ ប៉ះពាល់ដល់សមាជិកក្រុមហ៊ុនប៉ុណ្ណោះទេ ដូច្នេះហើយក្រុមហ៊ុនមួយអាចនឹងត្រូវបានរំលាយទៅវិញ ដោយ

[27] មាត្រា ២៨, ៣៨, ៣៣ ជំពូកទី ២ ច្បាប់ស្តីពី វិ.ពា.កម្ម និងបញ្ជីពាណិកម្ម(០៣.០៥.១៩៩៥)។

យោងទៅលើលក្ខខណ្ឌមួយចំនួន ដូចជា (១) ការរំលាយក្រុមហ៊ុនយោងតាមឆន្ទះរបស់សមាជិកក្រុមហ៊ុន, (២) ការរំលាយក្រុមហ៊ុនទៅតាមកម្មវត្ថុរបស់ក្រុមហ៊ុន, (៣) ក្រុមហ៊ុនក្ស័យធន, និង (៤) ការជម្រះបញ្ជីក្រុមហ៊ុន។

### ៣.១- ការរំលាយក្រុមហ៊ុនយោងតាមឆន្ទះរបស់សមាជិកក្រុមហ៊ុន

ស្ថិតក្នុងទិដ្ឋភាពដូចគ្នាទៅនឹង ការបង្កើតឡើងនូវកិច្ចសន្យាក្រុមហ៊ុន ការបញ្ចប់ទៅវិញនៃក្រុមហ៊ុន ក៏អាចធ្វើឡើងទៅតាមរយៈឆន្ទៈរបស់សមាជិកក្រុមហ៊ុនផងដែរ។ ការរំលាយក្រុមហ៊ុនដែលមានការសម្រេចជាឯកច្ឆ័ន្ទ ដោយមានការព្រមព្រៀងគ្នាពីសមាជិកទាំងអស់របស់ក្រុមហ៊ុននឹងត្រូវបានច្បាប់ទទួលស្គាល់ នូវសុពលភាព ហើយវាគឺជាកត្តានៃការរំលាយក្រុមហ៊ុនផងដែរ។ ដូចទៅនឹងការកំណត់នៃមាត្រា៧១៣ វក្យខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងថា "ក្នុងករណីដែលមានមូលហេតុមិនអាចជៀសវាងបាន សមាជិកនីមួយៗរបស់ក្រុមហ៊ុន អាចទាមទារឲ្យរំលាយក្រុមហ៊ុនបាន។ វាកាន់តែបញ្ជាក់ ឲ្យកាន់តែច្បាស់នូវចេតនារបស់ច្បាប់ សម្រាប់ការរំលាយក្រុមហ៊ុនដោយបានគោរពទៅលើគោលជំហរ និងការសម្រេចចិត្តរបស់សមាជិកក្រុមហ៊ុន ទាំងអស់ ថាតើពួកគេនឹងសម្រេចធ្វើការរំលាយក្រុមហ៊ុន ដែលមិនបានផ្តល់ផលចំណេញដល់ពួកគេ ឬយ៉ាងណា។ ប៉ុន្តែ វាមិនមានន័យថា ឲ្យតែមានការព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទ គឺគ្រប់គ្រាន់សម្រាប់ធ្វើការរំលាយក្រុមហ៊ុននោះឡើយ។

### ៣.២- ការរំលាយក្រុមហ៊ុនទៅតាមកម្មវត្ថុរបស់ក្រុមហ៊ុន

ក្រុមហ៊ុនមួយអាចនឹងត្រូវរំលាយ ដោយយោងទៅលើកម្មវត្ថុរបស់ក្រុមហ៊ុននោះត្រូវបានបញ្ចប់ ពោលការបញ្ចប់កិច្ចការដែលជាកម្មវត្ថុរបស់ក្រុមហ៊ុននោះ ដោយស្របទៅតាមការកំណត់នៅក្នុងកម្មវត្ថុ តាំងពីពេលដែលសមាជិកក្រុមហ៊ុនធ្វើការស្នើសុំចុះបញ្ជីក្រុមហ៊ុនរបស់ខ្លួនមកម្ល៉េះ។ ត្រង់ចំនុច នេះផងដែរ ក៏មានកំណត់នៅក្នុងមាត្រា៥៣ ចំនុច "ក" នៃច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ បានចែងអំពី ក្រុមហ៊ុនសហកម្មសិទ្ធិត្រូវរំលាយដោយមូលហេតុដែលមានចែងក្នុងកិច្ចសន្យា ដូចជា គោលបំណងធ្វើអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់, គ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត, និងតាមការព្រមព្រៀងជាឯកច្ឆន្ទរបស់សហកម្មសិទ្ធិករទូទៅ។ ជារួមមក ប្រសិនបើកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់ ក្រុមហ៊ុននោះ ក៏នឹងត្រូវរំលាយផងដែរ។

## ៣.៣- ក្រុមហ៊ុនក្ស័យធន

កត្តាមួយទៀតដែលគេរមែងតែងតែ ជួបប្រទះនាពេលដែលក្រុមហ៊ុនហៀបនឹងរំលាយ គឺបណ្តាលមកពី កង្វះលទ្ធភាពផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬគ្មានលទ្ធភាពក្នុងការធ្វើអាជីវកម្មបន្តដែលនាំឲ្យក្រុមហ៊ុននោះ មិនអាចបន្តប្រតិបត្តិការណ៍របស់ខ្លួន ជាប្រក្រតី។ ការដែល គ្មានលទ្ធភាពក្នុងផ្នែកហិរញ្ញវត្ថុនេះ ត្រូវបានកំណត់ផងដែរ នៅក្នុងច្បាប់ស្តីពីក្ស័យធន ដែលមានកំណត់នូវវិធានសម្រាប់អនុវត្ត។

## ៣.៤- ការជម្រះបញ្ជីក្រុមហ៊ុន

ការជម្រះបញ្ជីក្រុមហ៊ុន គឺជានីតិវិធីចុងក្រោយនៃការទូរទាត់ក្នុងការរំលាយក្រុមហ៊ុន ហើយនៅពេលដែលធ្វើការរំលាយក្រុមហ៊ុន សិទ្ធិក្នុងការកាន់កាប់ ប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនត្រូវប្រគល់ឲ្យអ្នកជម្រះបញ្ជី ។ អ្នកជម្រះបញ្ជីត្រូវផ្ទុសកម្មភាពក្នុងនាមជាអ្នកចាត់ចែង លើទ្រព្យសម្បត្តិក្រុមហ៊ុន ដែលមានលក្ខណៈ ពេញលេញតែម្តង។ នៅក្នុងនីតិវិធី ជម្រះបញ្ជី អ្នកជម្រះបញ្ជីត្រូវយកទ្រព្យសម្បត្តិ ដែលនៅសល់ក្នុងក្រុមហ៊ុនទៅធ្វើការទូទាត់ បំណុលផ្សេងៗ ដែលអាចមានដូចជា បំណុលពន្ធរបស់រដ្ឋ និងបំណុលផ្សេងទៀត ទៅតាមសិទ្ធិបុរិមាជាមុន រួចទើបធ្វើការបែងចែកភាគទុន ពោលអ្នកជម្រះបញ្ជីត្រូវធ្វើការគណនា ឲ្យបានអស់នូវទ្រព្យបំណុលជាមួយតតីយជន ឬធ្វើការសងទៅតាមម្ចាស់បំណុលដែលមានអទិភាព។

អ្នកជម្រះបញ្ជី អាចជាបុគ្គលឯករាជ្យ ឬជាបុគ្គលមិនឯករាជ្យ វាអាស្រ័យទៅលើការសម្រេចក្នុងការជ្រើសរើសអ្នកជម្រះបញ្ជី របស់សមាជិកក្រុមហ៊ុន។ អ្នកជម្រះបញ្ជីរបស់ក្រុមហ៊ុន ត្រូវបញ្ចប់នីតិវិធីជម្រះបញ្ជី ដោយធ្វើការតម្កល់ទុកនូវ សេចក្តីជូនដំណឹងអំពីការបិទបញ្ជីនោះ នៅក្រសួងពាណិជ្ជកម្មតាមបែបបទដែលបានកំណត់ទុក ដោយច្បាប់។ ការតម្កល់ទុកឯកសារនេះ គឺជាការលុបចោលនូវនីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុននោះឯង ម្យ៉ាងវិញទៀត វាក៏ជានីតិវិធីមួយដែលធ្វើការបើកផ្សាយយ៉ាងទូលាយផងដែរ ទៅឲ្យម្ចាស់បំណុលជ្រាប។

## VI- ការចុះបញ្ជីអង្គការសមាគមជានីតិបុគ្គល

សមត្ថកិច្ចចុះបញ្ជីអង្គការ សមាគម គឺជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ[28]។ ដើម្បីបង្កើតសមាគមបាន ត្រូវមានសមាជិកស្ថាបនិកដែលមានសញ្ជាតិខ្មែរចំនួនពីម្ភៃមួយ(២១)នាក់ឡើងទៅ។ សមាជិកទាំងនេះត្រូវជ្រើសរើសថ្នាក់ដឹកនាំសមាគមយ៉ាងតិចប្រាំពីរ(៧)នាក់សំរាប់រៀបចំបែបបទ និងបំពេញលក្ខខណ្ឌស្នើចុះបញ្ជី។

### ១- លក្ខខណ្ឌនៃការបង្កើតអង្គការសមាគម

ដើម្បីបង្កើតអង្គការសមាគមមិនមែនរដ្ឋាភិបាលក្នុងស្រុកបាន ត្រូវមានអ្នកផ្តួចផ្តើមដែលមានសញ្ជាតិខ្មែរយ៉ាងហោចណាស់ ៣នាក់ឡើងទៅ[29]។ សមាជិកទាំងនោះ ត្រូវធ្វើការជ្រើសរើសប្រធានមួយរូបសម្រាប់រៀបចំបែបបទ និងបំពេញលក្ខខណ្ឌស្នើរសុំចុះបញ្ជី។

- លក្ខន្តិកៈរបស់សមាគម ឬអង្គការក្រៅរដ្ឋាភិបាលត្រូវមានចែងក្នុងចំណុចដូចខាងក្រោម[30] :
  - ឈ្មោះជាអក្សរពេញ អក្សរកាត់ និងសញ្ញាសម្គាល់
  - គោលបំណង និងទិសដៅ
  - វិធាននៃការជ្រើសរើស ការបញ្ចប់ ការបណ្តេញចេញ ការផ្លាស់ប្តូរ ការដកហូតតំណែងសមាជិក បុគ្គលិក ប្រធាន និងថ្នាក់ដឹកនាំ។
  - សិទ្ធិ និងភារកិច្ចរបស់សមាជិក ឬបុគ្គលិក
  - រចនាសម្ព័ន្ធ អាណិត្ត ភារកិច្ច ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គការដឹកនាំនានា
  - អង្គការដឹកនាំនានារួម សន្និបាត ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនាយក គណៈកម្មាធិការប្រតិបត្តិ ឬអង្គការសមមូល។
  - វិធាននៃការប្រជុំសាមញ្ញ និង វិសាមញ្ញនៃអង្គការដឹកនាំនានា
  - ប្រភពធនធាន និងទ្រព្យសម្បត្តិ
  - វិធាននៃការប្តូរឈ្មោះ ការប្តូរសញ្ញាសម្គាល់ ឬការធ្វើវិសោធកម្មលក្ខន្តិកៈ
  - វិធាននៃការរំលាយ និងការចាត់ចែងធនធាន ទ្រព្យសម្បត្តិនៅពេលត្រូវបានរំលាយ។

---

[28] មាត្រា៧ នៃពង្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលឆ្នាំ២០១០។

[29] មាត្រា៩ នៃពង្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលឆ្នាំ២០១០។

[30] មាត្រា១០ នៃពង្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលឆ្នាំ២០១០។

## ២- សំណុំលិខិតសុំចុះបញ្ជីសមាគម

ប្រធានសមាគមត្រូវដាក់ពាក្យសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោម[31] :

- ពាក្យសុំចុះបញ្ជី ដោយប្រធានសមាគម ០២ច្បាប់
- តារាងបញ្ជីឈ្មោះស្ថាបនិកចំនួនចាប់ពី ២១នាក់ឡើងទៅដោយមានបញ្ជាក់អំពីអាយុ ភេទ សញ្ជាតិ អាសយដ្ឋានអចិន្ត្រៃយ៍។ សមាជិកទាំងនោះត្រូវធ្វើការជ្រើសរើសថ្នាក់ដឹកនាំសមាគមយ៉ាងតិចចំនួន ៧នាក់ សម្រាប់រៀបចំបែបបទ និងបំពេញលក្ខខណ្ឌសុំចុះបញ្ជី។
- លិខិតបញ្ជាក់អាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់សមាគមដោយមានការទទួលស្គាល់ពីមេឃុំ ឬចៅសង្កាត់ ១ច្បាប់។
- លក្ខន្តិកៈចុះហត្ថលេខាដោយប្រធាន និងថ្នាក់ដឹកនាំសមាគមទាំងអស់ ២ច្បាប់
- ប្រវត្តិរូបសង្ខេបរបស់ថ្នាក់ដឹកនាំសមាគម យ៉ាងតិចចំនួន ៧នាក់ ក្នុងម្នាក់ ២ច្បាប់ ដោយមានបិទរូបថតបច្ចុប្បន្នទំហំ ៤x៦។
- បង្កាន់ដៃថ្លៃអាករចុះបញ្ជីសមាគម ១ច្បាប់។

## ៣- សំណុំលិខិតសុំចុះបញ្ជីអង្គការក្រៅរដ្ឋាភិបាល[32]

- ពាក្យសុំចុះបញ្ជី ដោយប្រធានអង្គការក្រៅរដ្ឋាភិបាល ០២ច្បាប់
- លិខិតបញ្ជាក់អាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់អង្គការ ដោយមានការទទួលស្គាល់ពីមេឃុំ ឬចៅសង្កាត់ ១ច្បាប់។
- លក្ខន្តិកៈចុះហត្ថលេខាដោយប្រធាន និងថ្នាក់ដឹកនាំអង្គការទាំងអស់ ២ច្បាប់
- ប្រវត្តិរូបសង្ខេបរបស់ថ្នាក់ដឹកនាំអង្គការ យ៉ាងតិចចំនួន ៣នាក់ ក្នុងម្នាក់ ២ច្បាប់ ដោយមានបិទរូបថតបច្ចុប្បន្នទំហំ ៤x៦។

[31] មាត្រា១៤ នៃពង្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលឆ្នាំ២០១០។
[32] មាត្រា១៥ នៃពង្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលឆ្នាំ២០១០។

- លិខិតប្រកាសគណនីធនាគារដែលបានផ្ញើរនៅធនាគារណាមួយ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា ១ច្បាប់។

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនឹងក្លាយជានីតិបុគ្គលបម្រើប្រយោជន៍សាធារណៈ ចាប់ពីថ្ងៃដែលក្រសួងមហាផ្ទៃចេញសេចក្តីសម្រេចចុះបញ្ជី[33]។

# VII- សេចក្តីសន្និដ្ឋាន និង អនុសាសន៍

## ១- សេចក្តីសន្និដ្ឋាន

យោងតាមការបកស្រាយខាងលើយើងអាចធ្វើការសន្និដ្ឋានបានថា សិទ្ធិរបស់នីតិបុគ្គល គឺជាសិទ្ធិមួយដែលផ្តល់នីតិបុគ្គលក្នុងការបង្កើតក្រុមហ៊ុន អង្គការ ឬ សមាគមនានា ដែលត្រូវចុះបញ្ជីនៅក្រសួងដែលពាក់ពន្ធ័ដើម្បីក្លាយជានីតិបុគ្គលដែលច្បាប់ទទួលស្គាល់ ។ ពីព្រោះដោយមានការរីកចំរើន និង អភិវឌ្ឍន៍យ៉ាងខ្លាំងក្នុងវិស័យនយោបាយសេដ្ឋកិច្ច និងវប្បធ៌ម សង្គមរបស់កម្ពុជា ជាប្រទេសមួយដែលបានប្រែក្លាយបរិបទរបស់ខ្លួនជាប្រទេសដែលប្រកប ដោយបរិយាកាសវិនិយោគ។ ការរីកចំរើនដែលគួរអោយកត់សំគាល់ជាងគេ គឺការរីកលូតលាស់ យ៉ាងឆាប់រហ័សនៃវិស័យវិនិយោគពាណិជ្ជកម្ម ។ ដូចនេះ ដើម្បីអាចបង្កើតជាក្រុមហ៊ុន ឬជាអង្គការ សមាគមមួយស្របច្បាប់នៅកម្ពុជា គ្រឹះស្ថានទាំងអស់ត្រូវចុះបញ្ជីជាមុនសិន ។ ដើម្បីអាចធ្វើការចុះបញ្ជីបាន ក្រុមហ៊ុន និង អង្គការ សមាគមនានាត្រូវជ្រើសរើសយកទំរង់ក្រុមហ៊ុន ឬ អង្គការសមាគម ទៅតាមប្រភេទដែលខ្លួនចង់បង្កើតការជ្រើសរើសទំរង់ក្រុមហ៊ុន ឬ អង្គការសមាគមនេះ ត្រូវធ្វើការចុះបញ្ជីនៅក្រសួងដោយ បំពេញបែបបទដែលតម្រូវ និង ធ្វើការចុះបញ្ជីទៅតាមប្រភេទក្រុមហ៊ុន ឬ អង្គការសមាគមហើយត្រូវសុំអាជ្ញាប័ណ្ណពីក្រសួងដែលពាក់ព័ន្ធ។

## ២- អនុសាសន៍

ហេតុដូច្នេះហើយ យើងសូមចូលរួមចំនែកក្នុងការជួយផ្សព្វផ្សាយនូវចំពោះចំនេះដឹងទាំងប៉ុន្មានដែលយើងទទួលបានជូន ទៅមហាជនអោយគាត់បានយល់ដឹងថាៈហេតុចាំបាច់ធ្វើការចុះបញ្ជីពាណិជ្ជកម្ម ឬអង្គការសមាគម? តើការចុះបញ្ជីពាណិជ្ជកម្ម ឬអង្គការសមាគមមានអត្ថប្រយោជន៍អ្វី? ការចុះបញ្ជីពាណិជ្ជកម្ម ឬអង្គការសមាគម គឺពិតជាឧបករណ៍ដ៏មានប្រសិទ្ធិភាពរបស់រដ្ឋ និង មានសារៈសំខាន់ណាស់ ចំពោះអង្គភាពអាជីវកម្ម ឬអង្គការសមាគមទាំងឡាយ ដោយតាមរយៈនៃការ

[33] មាត្រា១៥ វាក្យខណ្ឌ២ នៃពង្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលឆ្នាំ២០១០។

ចុះបញ្ជីពាណិជ្ជកម្មអង្គភាពអាជីវកម្ម ឬអង្គការសមាគម និងទទួលបាននូវ អត្ថប្រយោជន៍ធ្វើអោយដៃគូររបស់ខ្លួនមានភាពទុកចិត្តធ្វើអោយសាធារណៈជន អតិថិជន និង ម្ចាស់បំនុលមានភាពជឿជាក់ងាយស្រួលក្នុងការស្វែងរកហិរញ្ញវត្ថុពីធនាគារ ស្ថាប័នហិរញ្ញវត្ថុ និងពីអ្នកផ្តល់ប្រាក់កម្ចី ឬម្ចាស់ជំនួយទាំងក្នុងប្រទេសដែលផ្តល់មកឲ្យអង្គការសមាគមនានាជាភស្តុតាងបញ្ជាក់សំរាប់ការសុំលិខិតអនុញ្ញាតផ្សេងៗសំរាប់បំពេញបែបបទ ផ្តល់ជំនួយ ឬ ចូលដេញថ្លៃអាជីវកម្មសំរាប់ចុះកិច្ចសន្យាសហប្រតិបត្តិការ អាជីវកម្មសំរាប់ការបើកសាខា ឬការិយល័យតំណាងរបស់ខ្លួន នៅបណ្តាប្រទេសនានានៅលើពិភពលោក ចៀសផុតពីហានិភ័យដែលកើតមានឡើង។ ម្យ៉ាងទៀត ការចុះបញ្ជីពាណិជ្ជកម្ម ឬ អង្គការសមាគមនេះ មិនត្រឹមតែផ្តល់នូវអត្ថប្រយោជន៍ដល់ម្ចាស់សហគ្រាស ឬប្រធានអង្គការសមាគមទាំងនោះទេ ថែមទាំងបានជួយប្រទេសជាតិអោយមានការរីកចំរើនមួយភាពធំផងដែរ គឺបានផ្តល់អោយរដ្ឋទទួលបានថវិកាពីការចុះបញ្ជី និង ធ្វើអោយសេដ្ឋកិច្ច មានដំនើរការទៅមុខយ៉ាងរលូននិងរីកចំរើន ហើយក៏បានជួយរក្សាសណ្តាប់ធ្នាប់សាធារណៈ របស់សង្គមផងដែរ ព្រោះថាការចុះបញ្ជីបានរៀបចំកំនត់ប្រភេទ អង្គការ ឬ សមាគម ឬ ក្រុមហ៊ុនសហគ្រាសទៅតាមទ្រង់ទ្រាយច្បាស់លាស់ និង ទប់ស្កាត់ការប្រកបរបបអាជីវកម្ម ឬអង្គការសមាគមដោយខុសច្បាប់។ ទាំងនេះសុទ្ធតែជាប្រយោជន៍ដែលទទួលបានពីការចុះបញ្ជី ហេតុដូច្នេះហើយក្រសួងដែលពាក់ពន្ធ័គួរតែខិតខំបំពេញភារកិច្ច និង ចាត់វិធានការរិតបន្ដឹង ចំពោះអង្គការសមាគម ឬ សហគ្រាសណាដែលពុំទាន់ចុះបញ្ជីអោយមកចុះបញ្ជីតាមការកំនត់របស់ច្បាប់ អង្គការសមាគម និង ក្រុមហ៊ុនសហគ្រាសទាំងអស់ត្រូវតែមានការអនុវត្តន៍ និង គោរពច្បាប់ នាំអោយបណ្តាអង្គការសមាគមនានាដែលជាដៃគូរផ្តល់ជំនួយក្រៅប្រទេសគេកាន់តែមានទំនុកចិត្ត និង ហ៊ានធ្វើការវិនិយោគ និងផ្តល់នូវជំនួយកាន់តែច្រើន ឡើងដែលជាកត្តានាំអោយសេដ្ឋកិច្ចជាតិកាន់តែប្រសើរឡើង ទីផ្សារការងារសំរាប់ពលរដ្ឋខ្មែរ កាន់តែមានកំណើន និង កំរិតជីវភាពប្រជាពលរដ្ឋកាន់តែខ្ពស់ជាលំដាប់តាម។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១
## គំរូលក្ខន្តិកៈក្រុមហ៊ុន និងការណែនាំ
## (ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត)

**ប្រការ ១ :** នាមករណ៍ក្រុមហ៊ុន...........................................................................

**ប្រការ ២ :** កម្មវត្ថុអាជីវកម្ម.................................................................................

ISIC code : សូមជ្រើសរើស កូដ ដែលបញ្ជាក់ពីសកម្មភាពចំបងរបស់ក្រុមហ៊ុន

..........................................................................................................

..........................................................................................................

..........................................................................................................

ប្រសិនបើម្ចាស់ហ៊ុនដាក់ការរឹតត្បិតណាមួយ ទៅលើសកម្មភាពអាជីវកម្ម សូមបញ្ជាក់ខាងក្រោម :

..........................................................................................................

..........................................................................................................

..........................................................................................................

**ប្រការ ៣ :** អាសយដ្ឋានទីស្នាក់ការក្រុមហ៊ុនចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា :

..........................................................................................................

អាសយដ្ឋានទំនាក់ទំនងរបស់ក្រុមហ៊ុនចុះបញ្ជី បើមានផ្សេង..........................................

ឈ្មោះភ្នាក់ងារចុះបញ្ជីរបស់ក្រុមហ៊ុន...............................................................

**ប្រការ ៤ :** ថិរវេលានៃសកម្មភាពក្រុមហ៊ុនគឺ មានរយៈពេល.......................................

**ប្រការ ៥ :** ដើមទុន និងភាគហ៊ុនដែលអនុញ្ញាត

ដើមទុនរបស់ក្រុមហ៊ុនគឺ..........................................................................រៀល ។

ដើមទុននេះត្រូវបានបែងចែកជា................................................................ភាគហ៊ុន

ដែលភាគហ៊ុននីមួយៗ មានតម្លៃចារឹក .....................................................រៀល ។

**ប្រការ ៦ :** ក្នុងករណីប្រភេទភាគហ៊ុនបន្ថែមត្រូវបានអនុញ្ញាតបោះចេញ មានប្រភេទ ចំនួន និងតម្លៃចារឹក ។ សូមបញ្ជាក់ពី សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅនឹងប្រភេទនៃភាគហ៊ុននីមួយៗ ។ ប្រសិនបើមានភាគហ៊ុនតែមួយ ប្រភេទ ត្រូវបានបោះចេញ សូមបញ្ជាក់ថា "**មិនមាន**"

..........................................................................................................

**ប្រការ ៧ :** ក្នុងករណីមានការរឹតត្បិតពិសេសណាមួយទៅលើការផ្ទេរភាគហ៊ុន ដែលបានបញ្ជាក់ដោយម្ចាស់ហ៊ុន សូមថែង អោយបានច្បាស់ ។ ប្រសិនបើគ្មានការរឹតត្បិតទេ សូមបញ្ជាក់ថា "**គ្មាន**"

..........................................................................................................

ប្រការ ៨ : ក្នុងករណីមានការរឹតត្បិតពិសេសណាមួយទៅលើការប្រកាស និងការបែងចែកភាគលាភ ដែលបានបញ្ជាក់ដោយ ម្ចាស់ហ៊ុន សូមថែង អោយបានច្បាស់ ។ ប្រសិនបើគ្មានការរឹតត្បិតទេ សូមបញ្ជាក់ថា "**គ្មាន**"

..........................................................................................................

**ប្រការ ៩ :** អភិបាលក្រុមហ៊ុនត្រូវបានតម្រូវអោយផ្តល់អោយម្ចាស់ហ៊ុននូវទិន្នន័យហិរញ្ញវត្ថុ និងរបាយការណ៍សវនករ និងព័ត៌មានបន្ថែមទៀត ទាក់ទិននឹងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងលទ្ធផលប្រតិបត្តិការក្រុមហ៊ុន ។

**ប្រការ ១០ :** ក្រោយពេលឯកភាពអោយធ្វើការជម្រះបញ្ជី និងរំលាយក្រុមហ៊ុនដោយសេចក្តីសម្រេចពិសេសរបស់ម្ចាស់ហ៊ុន ក្រុមហ៊ុនត្រូវផ្ញើនូវសេចក្តីថ្លែងហេតុដើម្បីរំលាយក្រុមហ៊ុន ទៅអភិបាលក្រុមហ៊ុន ។

មរណភាព ឬអសមត្ថភាពរបស់ម្ចាស់ហ៊ុនណាម្នាក់មិនបណ្តាលអោយមានការរំលាយក្រុមហ៊ុនឡើយ ។ ក្រុមហ៊ុនអាចបន្ត សកម្មភាពរបស់ខ្លួនរវាងកម្មសិទ្ធិករស្របច្បាប់ ឬទាយាទរបស់ម្ចាស់ហ៊ុនដែលទទួលមរណភាព ឬអសមត្ថភាព និងម្ចាស់ហ៊ុនដទៃទៀត ។

**ប្រការ ១១ :** បុគ្គលដែលមានឈ្មោះ និងអាសយដ្ឋានដូចខាងក្រោមត្រូវបានតែងតាំងជាអភិបាលក្រុមហ៊ុន សម្រាប់អាណតិកំណត់ ដូចខាងក្រោម :

| ឈ្មោះអភិបាល/អាសយដ្ឋាន | អាណត្តិ |
|---|---|
| ........................................................ | ........................................................ |
| ........................................................ | ........................................................ |
| ........................................................ | ........................................................ |
| ........................................................ | ........................................................ |

**ប្រការ ១២ :** យើងទាំងអស់គ្នាដែលមានឈ្មោះ អាជីព សញ្ជាតិ អាសយដ្ឋាន និងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដូចមាននៅក្នុងបញ្ជីខាងក្រោម បានសម្រេចចិត្តបង្កើតក្រុមហ៊ុន ដូចមានចែងក្នុងលក្ខន្តិកៈនេះ ហើយយើងទាំងអស់គ្នាយល់ ព្រមទទួលយកចំនួនភាគហ៊ុននៅក្នុងដើមទុនរបស់ក្រុមហ៊ុនដូចបានបញ្ជាក់ :

| ឈ្មោះរបស់ម្ចាស់ហ៊ុន/អាជីព/សញ្ជាតិ/អាសយដ្ឋាន/អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន និងកាលបរិច្ឆេទ | ចំណែក |
|---|---|
| ............................................................................................ | ................. |
| ............................................................................................ | ................. |
| ............................................................................................ | ................. |

តាមរយៈការចុះហត្ថលេខាលើលក្ខន្តិកៈ ម្ចាស់ហ៊ុន និងអភិបាលទាំងអស់ ទទួលស្គាល់កាតព្វកិច្ច ដើម្បីអនុវត្តតាម វិធានគ្រប់គ្រង ក្រុមហ៊ុន ដែលមានចែងក្នុងច្បាប់ស្តីពីសហគ្រាស ពាណិជ្ជកម្ម ។ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតអាចកែប្រែលក្ខន្តិកៈរបស់ខ្លួន ផ្អែកតាមសេចក្តីសម្រេចពិសេសរបស់ម្ចាស់ហ៊ុន ។ ក្រោយពេលបង្កើតក្រុមហ៊ុនការបោះពុម្ពផ្សាយ នូវការចុះបញ្ជី ក្រុមហ៊ុនត្រូវធ្វើឡើងក្នុងរាជកិច្ច និងព្រឹត្តិបត្រពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ។

| ហត្ថលេខាម្ចាស់ហ៊ុន | កាលបរិច្ឆេទ |
|---|---|
| ........................................................ | ........................................................ |
| ........................................................ | ........................................................ |
| ........................................................ | ........................................................ |

## សេចក្តីណែនាំ

គំរូលក្ខន្តិកៈនេះនឹងត្រូវយកមកប្រើសម្រាប់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ។ ចំណុចបន្ថែមនានាអាចត្រូវ បានបញ្ចូលក្នុងលក្ខន្តិកៈក្រុមហ៊ុន អាស្រ័យលើចំណង់ចំណូល ចិត្តរបស់ម្ចាស់ហ៊ុន ។ គំរូនេះផ្តល់អោយនូវខ្លឹមសារមួយចំនួនតូចដែលត្រូវបានតម្រូវសម្រាប់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត :

(ក) ក្រុមហ៊ុនអាចមានម្ចាស់ហ៊ុនពី ២ ទៅ ៣០ នាក់ ។ ប៉ុន្តែ បុគ្គលម្នាក់អាចបង្កើតក្រុមហ៊ុនមួយបាន ហៅថា សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ។ លក្ខខណ្ឌតម្រូវសម្រាប់សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត គឺមានលក្ខណៈដូចគ្នាជាមួយក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែរ លើកលែងតែទំនាក់ទំនងរវាងម្ចាស់ហ៊ុន ចេញ ។

(ខ) ក្រុមហ៊ុនមិនអាចបោះចេញភាគហ៊ុន ឬមូលបត្រអោយទៅសាធារណៈជនទូទៅឡើយ ប៉ុន្តែអាចផ្តល់ភាគហ៊ុន ឬមូលបត្រទាំងនោះអោយទៅម្ចាស់ហ៊ុន សមាជិកក្រុមគ្រួសារ និងអ្នកគ្រប់គ្រង ។

(គ) ក្រុមហ៊ុនអាចមានការរឹតត្បិតមួយ ឬច្រើនលើការផ្ទេរប្រភេទភាគហ៊ុននីមួយៗរបស់ខ្លួន ។

**ប្រការ ១ :** នាមករណ៍របស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវបញ្ចូលពាក្យ "ក្រុមហ៊ុនឯកជនទទួលខុស ត្រូវមានកម្រិត ។ នាមករណ៍របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវដាក់នូវពាក្យថា "ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត" ។ នាមករណ៍ក្រុមហ៊ុនត្រូវសរសេរ ជាភាសាខ្មែរ ហើយការបកប្រែនាមករណ៍ពីភាសាមួយទៅ ភាសាមួយទៀត ត្រូវហាមឃាត់ ។

**ប្រការ ២ :** សូមមើលតារាងក្នុងឧបសម្ព័ន្ធ និងជ្រើសរើសអ្វីដែលសមហេតុផលបំផុត ។ ជ្រើសរើសកូដ ដែលបញ្ជាក់ពី សកម្មភាពចំបងរបស់ក្រុមហ៊ុន ។

**ប្រការ ៣ :** ផ្តល់អាសយដ្ឋានស្នាក់ការក្រុមហ៊ុនពិតប្រាកដ និងអាសយដ្ឋាន ទំនាក់ទំនង ។ លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរ ទីតាំងរបស់ទីស្នាក់ការចុះបញ្ជី ត្រូវផ្ញើទៅមន្ត្រីទទួល

បន្ទុក គ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរនោះ ។ ភ្នាក់ងារចុះបញ្ជីសំដៅលើរូបវន្តបុគ្គលដែលមានសមត្ថភាពផ្លូវច្បាប់ ជាបុគ្គល ដែលមានសិទ្ធិអំណាចទទួលលិខិតស្នាម និងឯកសារផ្លូវការ រួមមានដូចជាដីកាកោះ និងដីកាកោះសាក្សី ពីតុលាការ តាងនាម អោយក្រុមហ៊ុន ។ ភ្នាក់ងារចុះបញ្ជីរបស់ក្រុមហ៊ុន ត្រូវតែជាបុគ្គលដែលមាន សមត្ថភាពតាមផ្លូវច្បាប់ ដែលអនុញ្ញាត អោយទទួលនូវ លិខិតស្នាម ឬឯកសារផ្លូវការ រួមមាន ដីកា និងការកោះអញ្ជើញរបស់តុលាការក្នុងនាមក្រុមហ៊ុន ។

**ប្រការ ៤ :** រយៈពេលនៃក្រុមហ៊ុនអាចកំណត់ដោយអ្នកស្ថាបនិក ។ រយៈពេលនៃក្រុមហ៊ុនអាចមិនមានពេលកំណត់ ។

**ប្រការ ៥ :** លក្ខន្តិកៈក្រុមហ៊ុនត្រូវ ចែងពីចំនួនភាគហ៊ុនដែលត្រូវបានអនុញ្ញាត អោយបោះចេញដោយក្រុមហ៊ុន និងតម្លៃ ចារឹក នៃភាគហ៊ុននីមួយៗ ។

**ប្រការ ៦ :** ក្នុងករណីក្រុមហ៊ុនបោះចេញភាគហ៊ុនលើសពីមួយប្រភេទ នោះត្រូវបញ្ជាក់ពីសិទ្ធិឯកសិទ្ធិការរឹតត្បឹតនិងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅ នឹងប្រភេទភាគហ៊ុននីមួយៗ ។

**ប្រការ ៧ :** ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មអនុញ្ញាត អោយធ្វើអនុប្បទានទៅសមាជិកភាគហ៊ុន សមាជិកគ្រួសារ និងអ្នក គ្រប់គ្រងបានដោយសេរី ។ក្នុងករណីធ្វើអនុប្បទានទៅអោយតតិយជនត្រូវ មានការយល់ព្រមពីសមាជិកភាគហ៊ុន ដទៃទៀត តាមសម្លេងភាគច្រើន ។ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មចែងថា ការរឹតត្បឹតបន្ថែមទៀតលើការធ្វើអនុប្បទាន ត្រូវចែង ក្នុងលក្ខន្តិកៈ ។

**ប្រការ ៨ :** អភិបាលអាចប្រកាសចេញនូវ ភាគលាភសល់ ឬ ប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុន ដើម្បីចែកជូនម្ចាស់ហ៊ុន ។ ការរឹតត្បិតអាចចែងនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន ។ មាត្រា ១៥៧ - ១៥៩ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មមានចែងពីវិធាននិងការរឹតត្បឹតលើការបែងចែកភាគលាភ ។

**ប្រការ ៩ :** ផ្អែកតាមមាត្រា ២២៤-២៣៤ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម អភិបាលក្រុមហ៊ុនត្រូវមានកាតព្វកិច្ចផ្តល់ អោយម្ចាស់ហ៊ុននូវរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សវនកម្ម និងព័ត៌មានបន្ថែមទៀតណាមួយទាក់ទិននឹងស្ថានភាពហិរញ្ញវត្ថុក្រុមហ៊ុននិងលទ្ធផលនៃប្រតិបត្តិការរបស់ខ្លួនដែលតម្រូវដោយលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង ឬកិច្ចព្រមព្រៀងជាឯកច្ឆ័នរបស់ ម្ចាស់ហ៊ុនណាមួយ ។

**ប្រការ ១០ :** មាត្រា ២៥១-២៥៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម បញ្ជាក់អំពីលក្ខខណ្ឌតម្រូវអោយម្ចាស់ភាគហ៊ុននិងអភិបាលដាក់ស្នើនិងអនុម័តការរំលាយក្រុមហ៊ុន ព្រមទាំងលក្ខខណ្ឌតម្រូវសម្រាប់រៀបចំសេចក្តីថ្លែងហេតុ និងលិខិតជូនដំណឹង អំពីការរំលាយក្រុមហ៊ុន ។ មាត្រាទាំងនេះក៏រួមមានបញ្ញត្តិស្តីពីការជម្រះបញ្ជី និងលក្ខខណ្ឌតម្រូវអោយ ក្រុមហ៊ុនដាក់នូវសេចក្តី-សម្រេចរំលាយក្រុមហ៊ុន ផងដែរ ។បញ្ញត្តិស្តីពីការរំលាយ និងការជម្រះបញ្ជីមិនត្រូវអនុវត្តចំពោះក្រុមហ៊ុនដែលបានដាក់ពាក្យសុំ ក្ស័យធនទៅតុលាការឡើយ ។

**ប្រការ ១១ :** មាត្រា១២១នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មមានចែងថាអាណត្តិអភិបាលម្នាក់ៗត្រូវមានអាណត្តិ០២(ពីរ) ឆ្នាំហើយបានបញ្ជាក់ថាលក្ខន្តិកៈអាចចែងផ្សេងពីនេះ ។ មាត្រា ១១៦ ចែងថា អភិបាលដំបូងត្រូវកាន់តំណែង ចាប់ពីកាលបរិច្ឆេទនៃការបង្កើតក្រុមហ៊ុនរហូតដល់មានមហាសន្និបាតម្ចាស់ហ៊ុនលើកដំបូង ។មាត្រា១២៤ចែងថាអភិបាលអាចត្រូវដកហូតចេញពីមុខតំណែងបាន ដោយសម្លេងភាគច្រើនដាច់ខាតនៃម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត ទោះជាមាន ឬគ្មានមូលហេតុក៏ដោយ ។ មាត្រា ១១៦ - ១៤២ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មមានចែងពីតួនាទី ការទទួលខុសត្រូវ និងការជ្រើសរើសអភិបាល ។ សិទ្ធិអំណាចរបស់អភិបាលមានចែងក្នុងមាត្រា ១១៩ នៃច្បាប់ស្តីពីសហគ្រាស ពាណិជ្ជកម្ម លក្ខន្តិកៈក្រុមហ៊ុនចែងពីសិទ្ធិរបស់អភិបាលដែលមានជាអាទិ៍ :

១. តែងតាំង និងដកហូតអ្នកគ្រប់គ្រងទាំងអស់ និងកំណត់នូវសិទ្ធិច្បាស់លាស់សម្រាប់អ្នកគ្រប់គ្រងទាំងនោះ ។

២. កំណត់ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗដល់អ្នកគ្រប់គ្រងទាំងនោះ ។

៣. កម្រិតប្រាក់បៀវត្ស ឬប្រាក់បំណាច់ផ្សេងៗ សម្រាប់អភិបាលទាំងឡាយ ហើយដាក់ជូនទៅម្ចាស់ហ៊ុនដើម្បីសុំ សេចក្តីសម្រេច ។

៤. ចេញប័ណ្ណកំណត់សន្យា សញ្ញាប័ណ្ណ និងលិខិតស្នាមដែលបញ្ជាក់ថាមានបំណុល និងតឹកតាងផ្សេងៗនៃបំណុលរបស់ ក្រុមហ៊ុន និងកំណត់នូវលក្ខណៈដាច់ខាត និងលក្ខណៈផ្សេងរបស់លិខិតស្នាមទាំងឡាយនោះ ។

៥. ស្នើសុំម្ចាស់ហ៊ុន ដើម្បីធ្វើការកែប្រែលក្ខន្តិកៈ ឬលុបចោលលក្ខន្តិកៈរបស់ក្រុមហ៊ុន។

៦. ស្នើសុំម្ចាស់ហ៊ុននូវកិច្ចសន្យារំលាយចូលគ្នា ឬរួមបញ្ចូលគ្នារវាងក្រុមហ៊ុន និងបុគ្គលផ្សេងណាមួយ ។

៧. ស្នើសុំម្ចាស់ហ៊ុន ដើម្បីលក់ទ្រព្យសកម្មរបស់ក្រុមហ៊ុនទាំងអស់ ឬមួយភាគ ។

៨. ស្នើសុំម្ចាស់ហ៊ុនដើម្បីរំលាយ ឬជម្រះបញ្ជីក្រុមហ៊ុន ។

៩. ប្រកាសភាគលាភទៅតាមគោលការណ៍គណនេយ្យ និងតាមលក្ខខណ្ឌនៃការដាក់ភាគហ៊ុនប្រភេទនីមួយៗដែលមានសិទ្ធិ ទទួលភាគលាភ ។

១០. ចេញប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនទៅតាមវិសាលភាព ដែលបានចែងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

១១. ខ្ចីប្រាក់ ។

១២. បោះចេញសាជាថ្មី ឬលក់មូលបត្ររបស់ក្រុមហ៊ុន ។

១៣. ចុះកិច្ចសន្យាធានា ក្នុងនាមក្រុមហ៊ុន ។

១៤. ធ្វើអ៊ីប៉ូតែក ចុះកិច្ចសន្យាបញ្ចាំ បើមិនដូច្នេះទេបង្កើតផលប្រយោជន៍ ពីមូលបត្រចំពោះទ្រព្យសម្បត្តិទាំងអស់ ឬ ទ្រព្យសម្បត្តិណាមួយរបស់ក្រុមហ៊ុនដើម្បី ធ្វើការធានាកាតព្វកិច្ចណាមួយរបស់ក្រុមហ៊ុន ។

១៥. រៀបចំការបិទបញ្ជីគណនេយ្យនៃកាលបរិច្ឆេទនីមួយៗជូនម្ចាស់ហ៊ុន និងស្នើចាត់ចែងលទ្ធផលប្រចាំឆ្នាំដាក់ជូន មហាសន្និបាតនៃម្ចាស់ហ៊ុន ។

**ប្រការ ១២**:បញ្ជាក់ឈ្មោះរបស់ម្ចាស់ហ៊ុន អាជីព សញ្ជាតិ អាសយដ្ឋាន លេខលិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណ ។ផ្តល់អោយ ចំនួនភាគហ៊ុនកំណត់សម្រាប់ម្ចាស់ហ៊ុននីមួយៗ ។

តាមរយៈការចុះហត្ថលេខាលើលក្ខន្តិកៈ ម្ចាស់ហ៊ុន និងអភិបាលទាំងអស់យល់ព្រមទទួលស្គាល់កាតព្វកិច្ច ដើម្បីអនុវត្តតាម វិធានគ្រប់គ្រងក្រុមហ៊ុន ដែលមានចែងក្នុងច្បាប់ស្តីពី សហគ្រាស ពាណិជ្ជកម្ម ។ ម្ចាស់ហ៊ុនទាំងអស់ត្រូវចុះហត្ថលេខាលើលក្ខន្តិកៈ ។ ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន តម្រូវអោយមាននូវសេចក្តីសម្រេចពិសេស របស់ម្ចាស់ហ៊ុន ដែលអ្នកកាន់កាប់ប្រភេទ ឬស៊េរីនៃភាគ ហ៊ុននីមួយៗត្រូវបោះឆ្នោតផ្សេងពីគ្នាតាមប្រភេទ ឬស៊េរីភាគហ៊ុន ។ ដោយចុះហត្ថលេខាលើលក្ខន្តិកៈក្រុមហ៊ុន ម្ចាស់ហ៊ុន និងអភិបាលយល់ព្រមគោរពតាមមាត្រា ២៣៥-២៤០ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលមានចែងអំពីនីតិវិធី និងលក្ខណៈ នៃការកែប្រែនោះ ។

## លក្ខខណ្ឌតម្រូវបន្ថែមដែលចែងដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

១. ក្រុមហ៊ុននីមួយៗ មានកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅ ក្រសួង ពាណិជ្ជកម្ម ។

